**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

*លេខៈ១៣៦ សរក*

*ថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ១១ ឆ្នាំ២០២១*

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារនព្វមាស ឆ្នាំ២០២១ និងទិសដៅការងារសម្រាប់អនុវត្តបន្ត របស់ក្រសួងមហាផ្ទៃ

អំឡុងពេល ០៩ខែ ដើមឆ្នាំ២០២១ នេះ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្រោមការរាតត្បាតនៃជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មី ការវិវត្តប្រែប្រួលនៃសភាពការណ៍សន្តិសុខពិភពលោក រួមទាំងការប៉ុនប៉ងបង្កភាពចលាចលក្នុងសង្គម បំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុងជាតិតាមបែបផែនបដិវត្តន៍ពណ៌ ពីសំណាក់ពួកឧទ្ទាមក្រៅច្បាប់ផងដែរ ។ ទោះបីយ៉ាងនេះក្តី ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា យើងនៅតែរក្សាបាននូវខឿនសន្តិសុខជាតិ ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់នៅក្នុងសង្គមទាំងមូល ដែលក្នុងនោះ ក្រសួងមហាផ្ទៃបានដើរតួនាទីដ៏សំខាន់ និងសកម្មផុលផុសក្នុងការសម្របសម្រួលអនុវត្តបទបញ្ជា និងវិធានការនានារបស់រាជរដ្ឋាភិបាល ព្រមទាំងការងារអាទិភាពជាច្រើនទៀតក្នុងក្របខ័ណ្ឌនៃតួនាទី ភារកិច្ចរបស់ក្រសួងមហាផ្ទៃ ដែលជាមូលដ្ឋានស្នូលបម្រើដល់ការសម្រេចបានសមិទ្ធផលរួមខាងលើ និងការរស់នៅប្រកបដោយភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ ។

ជាក់ស្តែង សកម្មភាព និងលទ្ធផលការងារដែលក្រសួងសម្រេចបាន និងកំពុងអនុវត្តបន្ត មានជាអាទិ៍ ៖

## I-លទ្ធផលការងារសម្រេចបាន

### ១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្នុងរយៈពេល ០៩ខែ នេះ មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាច្រើន ដែលក្រសួងមហាផ្ទៃ បាន និងកំពុងជំរុញរៀបចំតាក់តែងសម្រាប់ជាមូលដ្ឋានជំរុញ និងគាំទ្រដល់ការអនុវត្តកិច្ចការនានាក្រោមដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងនោះរួមមាន ៖

➢ ***ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន***

- ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងលើកលែងទោស
- អនុក្រឹត្យស្តីពី ការបង្កើតក្រុងបូកគោ នៃខេត្តកំពត
- អនុក្រឹត្យស្តីពី ការកំណត់ចំនួនគណៈអភិបាលក្រុងបូកគោ នៃខេត្តកំពត
- អនុក្រឹត្យស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុងបូកគោ នៃខេត្តកំពត សម្រាប់អាណត្តិទី១
- អនុក្រឹត្យស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥

- អនុក្រឹត្យស្តីពី ការបង្កើតឃុំយាយម៉ៅពេជ្រនិល នៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- អនុក្រឹត្យស្តីពី ការបង្កើតឃុំភ្នំក្រាំងដីមាស នៃស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- អនុក្រឹត្យស្តីពី ការបង្កើតឃុំអូរកណ្តៀរសែនជ័យ នៃស្រុកសំបូរ ខេត្តក្រចេះ
- អនុក្រឹត្យស្តីពី ការបង្កើតឃុំឬស្សីរិល នៃស្រុកបវេល ខេត្តបាត់ដំបង
- អនុក្រឹត្យស្តីពី ការបង្កើតសង្កាត់អូរជ្រៅ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អនុក្រឹត្យស្តីពី ការបង្កើតសង្កាត់អូរឫស្សី នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អនុក្រឹត្យស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំបឹងល្វា ជាមួយឃុំកំពង់ថ្ម និងឃុំប្រាសាទ នៃស្រុកសន្ទុក ខេត្តកំពង់ធំ
- អនុក្រឹត្យស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំសំបូរ ជាមួយឃុំវឌ្ឍនៈ និងឃុំប្រាសាទ នៃស្រុកសំបូរ ខេត្តក្រចេះ
- អនុក្រឹត្យស្តីពី ការដំឡើង និងការកែសម្រួលរចនាសម្ព័ន្ធសាលាជាតិរដ្ឋបាលមូលដ្ឋាន ស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ

➢ ***ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលកំពុងតាក់តែង***

- សេចក្តីព្រាងច្បាប់ស្តីពី សណ្តាប់ធ្នាប់សាធារណៈ
- សេចក្តីព្រាងច្បាប់ស្តីពី នគរបាលជាតិកម្ពុជា
- សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម (គ.ជ.ប.ទ)
- សេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន
- សេចក្តីព្រាងច្បាប់ស្តីពី អន្តោប្រវេសន៍ថ្មី នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក
- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- សេចក្តីព្រាងការកែសម្រួលព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី គោរមងារឧកញ៉ា
- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ឯកសណ្ឋានរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងសន្តិសុខ និងអ្នកស្នាក់នៅតាមតំបន់ប្រមូលផ្តុំ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការផ្តល់របបឧបត្ថម្ភសម្រាប់ឋានៈសាស្ត្រាចារ្យ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន)
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

- សេចក្ដីព្រាងអនុក្រឹត្យស្ដីពី គោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ខេត្ត និងការកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្ដីព្រាងអនុក្រឹត្យស្ដីពី គ្រូនគរបាលជាតិ
- សេចក្ដីព្រាងការកែសម្រួលអនុក្រឹត្យលេខ ១០៩អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- សេចក្ដីព្រាងការកែសម្រួលអនុក្រឹត្យលេខ ១៥៦អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រៅពីលិខិតបទដ្ឋានគតិយុត្តខាងលើ ក្រសួងបានរៀបចំ និងដាក់ចេញឱ្យអនុវត្តនូវប្រកាស សេចក្ដីសម្រេច និងសេចក្ដីណែនាំ ក៏ដូចជាបទបញ្ជាផ្សេងៗជាច្រើនទៀត ដែលពាក់ព័ន្ធក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ។

**ខ-ការងារគ្រប់គ្រងរដ្ឋបាលដែនដី**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានរាជធានីចំនួន ០១ ខេត្ត ២៤ ក្រុង ២៨ ស្រុក ១៦២ ខណ្ឌ ១៤ ឃុំ ១.៤០៦ សង្កាត់ ២៤៦ និងភូមិចំនួន ១៤.៤៤២។ **<u>កត់សម្គាល់៖</u>** ក្នុងឆ្នាំ២០២១ នេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតក្រុងថ្មីចំនួន ០១ (ចំណុះរដ្ឋបាលខេត្តកំពត) ឃុំថ្មីចំនួន ០៤ (ចំណុះរដ្ឋបាលខេត្តកំពង់ស្ពឺ ០១ឃុំ កំពង់ឆ្នាំង ០១ឃុំ ក្រចេះ ០១ឃុំ និងខេត្តបាត់ដំបង ០១ឃុំ) សង្កាត់ថ្មីចំនួន ០២ (ចំណុះរដ្ឋបាលខេត្តបន្ទាយមានជ័យ) ភូមិថ្មីចំនួន ៣៧ (ចំណុះរដ្ឋបាលខេត្តក្រចេះ) និងកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំមួយចំនួនក្នុងខេត្តកំពង់ធំ និងខេត្តក្រចេះ ។

**គ-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**គ.១-ការផ្ដល់សេវា និងការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលនៃកិច្ចដំណើរការរបស់អង្គភាព-ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងរយៈពេល ០៩ខែ ឆ្នាំ២០២១ មានដូចខាងក្រោម ៖

-អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង ២៥គោលដៅ ផ្ដល់សេវារដ្ឋបាលបាន ៣២៧.០២៧ សេវា/១៤វិស័យ និងទទួលបានចំណូលសរុប ៦១.១៦៧.០៣១.៧០១រៀល សមមូល ១៥.២៩១.៧៥៧,៩២ ដុល្លារ។ ទន្ទឹមគ្នានេះ ការិយាល័យប្រជាពលរដ្ឋទាំង ២៥គោលដៅ ទទួលបានពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗ សរុប ១.០៤៣ករណី ក្នុងនោះ បណ្ដឹងពាក់ព័ន្ធសមត្ថកិច្ចក្រសួងមហាផ្ទៃ ៦៦០ករណី (ដោះស្រាយរួច ៥៣៨ ករណី) រីឯ ៣៨៣ករណីទៀត ជាបណ្ដឹងក្រៅសមត្ថកិច្ច សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗ ។

-ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌចំនួន ១១៥គោលដៅ ផ្ដល់សេវារដ្ឋបាលបាន ១.៣៦២.៣៦០សេវា/១៤វិស័យ ទទួលបានចំណូលសរុប ១១.៩៧៣.៤៩០.០៦៩រៀល សមមូល ២.៩៩៣.៣៧២,៥១ ដុល្លារ ។ ទន្ទឹមនេះ ការិយាល័យប្រជាពលរដ្ឋចំនួន ១១៥គោលដៅ ទទួលបានពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗ សរុប ៨.៥៩៤ករណី ក្នុងនោះ បណ្ដឹងពាក់ព័ន្ធសមត្ថកិច្ចក្រសួងមហាផ្ទៃ ២២១ករណី (បញ្ចប់ការដោះស្រាយ ២១៩) រីឯ ៨.៣៧៣ករណីទៀត ជាបណ្ដឹងក្រៅសមត្ថកិច្ច សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗ ។

**គ.២-ការគាំទ្រ និងការសម្របសម្រួលការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

-សហការ សម្របសម្រួលជាមួយ គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំឯកសារបណ្ដុះបណ្ដាលស្ដីពី ការគ្រប់គ្រងការងារអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការតាមដានព័ត៌មានពាក់ព័ន្ធនឹងការដាក់ចេញសេចក្ដីសម្រេចស្ដីពី វិធានការរដ្ឋបាល និងការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលមិនគោរពវិធានការរដ្ឋបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយ

គ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតរបស់រដ្ឋបាលរាជធានី ខេត្ត ការរៀបចំសេចក្តីព្រាងដីកាពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូទឹកកខ្វក់ ការប្រមូលព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងមណ្ឌលកុមារកំព្រានៅតាមបណ្តារាជធានី ខេត្ត ការសិក្សារៀបចំគម្រោងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសម្រាម និងប្លាស្ទិកនៅកម្ពុជា ការកែសម្រួលតម្លៃសេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលខេត្តព្រះសីហនុ និងការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ ។

-ចាត់មន្ត្រីចំនួន ០២រូប ចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាល និងជនបង្គោល នៅក្នុងការអនុវត្តគម្រោងស្តីពីការទប់ស្កាត់សំណល់ប្លាស្ទិកសមុទ្រកម្ពុជា ។

**ក.៣-ការគាំទ្រ និងតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ វឌ្ឍនភាពនៃការរៀបចំផែនការ និងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ រួមមានជាអាទិ៍ ៖

-រដ្ឋបាលក្រុង ស្រុក ទាំង១៨៩ ៖ ការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២១-២០២៣ បានបញ្ចប់ជាស្ថាពរ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ជំហានទី១ (បានបញ្ចប់ ៩៥%) និងជំហានទី២ (បានបញ្ចប់ ៣៥%)។ ដោយឡែក ចំពោះការរៀបចំកសាងផែនការអភិវឌ្ឍប្រាំឆ្នាំ២០២០-២០២៤ ក៏បានបញ្ចប់ជាស្ថាពរផងដែរ ។

-រដ្ឋបាលឃុំ សង្កាត់ទាំង ១.៦៤៦៖ ការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២១-២០២៣ បានបញ្ចប់ជាស្ថាពរ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ជំហានទី១ (បានបញ្ចប់ ៩៦%) និងជំហានទី២ (បានបញ្ចប់ ២៩%)។ ដោយឡែក ចំពោះការរៀបចំកសាងផែនការអភិវឌ្ឍប្រាំឆ្នាំ២០១៧-២០២២ ក៏បានបញ្ចប់ជាស្ថាពរផងដែរ ។

-គម្រោងមូលនិធិក្រុង ស្រុក ដែលបានគ្រោងឡើងក្នុងឆ្នាំ២០២០ សរុបចំនួន ៥១៦គម្រោង រួមមានគម្រោងបានដាក់ឱ្យដេញថ្លៃរួច ៤៨៧គម្រោង (ចុះកិច្ចសន្យាសាងសង់រួច ៤៨៧គម្រោង ក្នុងនោះ អនុវត្តចប់ជាស្ថាពរ) បញ្ចប់ការសិក្សា ១៥គម្រោង និងមិនទាន់សិក្សា ១៤គម្រោង។ ដោយឡែក គម្រោងមូលនិធិក្រុង ស្រុក ដែលបានគ្រោងឡើងក្នុងឆ្នាំ២០២១ សរុបចំនួន ៤៤២គម្រោង រួមមាន គម្រោងបានដាក់ឱ្យដេញថ្លៃរួច ១៥៧គម្រោង (ចុះកិច្ចសន្យាសាងសង់រួច ១១២គម្រោង ក្នុងនោះ អនុវត្តចប់ជាស្ថាពរ ៤៧គម្រោង កំពុងអនុវត្ត ២៦គម្រោង និងមិនទាន់សិក្សា ៣៩គម្រោង) បញ្ចប់ការសិក្សា ១៣៧គម្រោង កំពុងសិក្សា ១២២គម្រោង និងមិនទាន់សិក្សា ២៦គម្រោង ។

-គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានគ្រោងឡើងក្នុងឆ្នាំ២០២០ សរុបចំនួន ២.០៤៩គម្រោង រួមមានគម្រោងបានដាក់ឱ្យដេញថ្លៃរួច ១.៩៣៥គម្រោង (ចុះកិច្ចសន្យាសាងសង់រួច ១.៩៣១គម្រោង ក្នុងនោះ អនុវត្តចប់ជាស្ថាពរ ១.៨៤៧គម្រោង កំពុងវត្ត ៧៩គម្រោង និងមិនទាន់អនុវត្ត ០៥គម្រោង) បញ្ចប់ការសិក្សា ១១៤គម្រោង ។ ដោយឡែក គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានគ្រោងឡើងក្នុងឆ្នាំ២០២១ សរុបចំនួន ១.៨៤៧គម្រោង រួមមាន គម្រោងបានដាក់ឱ្យដេញថ្លៃរួច ៩២៨គម្រោង (ចុះកិច្ចសន្យាសាងសង់រួច ៨០៣គម្រោង ក្នុងនោះ អនុវត្តចប់ជាស្ថាពរ ១៩០គ្រោង កំពុងអនុវត្ត ២៧៨គម្រោង និងមិនទាន់អនុវត្ត ៣៣៥គម្រោង) បញ្ចប់ការសិក្សា ៥៩២គម្រោង កំពុងសិក្សា ៣១៦គម្រោង និងមិនទាន់សិក្សា ៥១គម្រោង។

**ក.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងគម្រោងនានា**

-កម្មវិធីមូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF)៖ សកម្មភាព និងលទ្ធផលសំខាន់ៗ រួមមាន បានរៀបចំចប់ជាស្ថាពរនូវសៀវភៅណែនាំស្តីពី កម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

សៀវភៅណែនាំស្តីពី កិច្ចការពារកុមារឃុំ សង្កាត់ សៀវភៅណែនាំស្តីពី ការប្រើប្រាស់ប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ សេចក្តីណែនាំស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងអនុម័តថវិការបស់ឃុំ សង្កាត់ សេចក្តីណែនាំស្តីពី ការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាល ឃុំ សង្កាត់ និងឯកសារបណ្តុះបណ្តាលស្តីពី ការអនុវត្តសកម្មភាពសេវាសង្គមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាសរុបចំនួន ១៩លើក។ កែសម្រួលប្រព័ន្ធទិន្នន័យអនឡាញសម្រាប់តាមដាន និងត្រួតពិនិត្យការអនុវត្តសេវាសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកែសម្រួលទម្រង់របាយការណ៍រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីនេះក៏បានរៀបចំផ្ទេរថវិកា UNICEF ទៅឱ្យ គ.ជ.ប.ជ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាពរបស់មន្ត្រីបម្រើការងារនៅតាមមណ្ឌលចត្តាឡីស័ក និងមន្ត្រីរាជរដ្ឋាភិបាលនៅតាមច្រកទ្វារព្រំដែនផងដែរ ។

**-គម្រោងលើកកម្ពស់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច គាំទ្រដោយអង្គការភ្លែនអន្តរជាតិ ៖** សកម្មភាពសំខាន់ៗ រួមមាន រៀបចំសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងាររៀបចំឯកសារណែនាំដល់ឃុំ សង្កាត់ អំពីការលើកកម្ពស់ការគាំពារ និងអភិវឌ្ឍកុមារតូច និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីថវិកា និងកិច្ចលទ្ធកម្មរបស់គម្រោងកិច្ចគាំពារ និងអភិវឌ្ឍកុមារតូច ។

**-គម្រោងសាងសង់អគាររដ្ឋបាល និងអគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ (DCOCP)** គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ វឌ្ឍនភាពនៃដំណើរការសាងសង់គម្រោងសម្រេចបាន ៩៨% ។

### ក.៥-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងបានគោរពស្នើសុំរាជរដ្ឋាភិបាលផ្តល់នូវគោរមងារឧកញ៉ា ១៨រូប និងគ្រឿងឥស្សរិយយស រួមមានមេដាយជាតូបការ ០៤គ្រឿង ព្រះរាជាណាចក្រកម្ពុជា ១០គ្រឿង មុនីសារភណ្ឌ ៦៣គ្រឿង ស្ថាបនាជាតិ ២៨គ្រឿង និងមេដាយការងារ ០១គ្រឿង ដើម្បីសម្តែងនូវការដឹងគុណដល់សប្បុរសជនដែលបានចំណាយថវិកាផ្ទាល់ខ្លួនសរុបចំនួន ១៧.៦៦៩.៤៩១ដុល្លារ ក្នុងការចូលរួមកសាងសមិទ្ធផលនានាជាច្រើននៅខេត្តព្រៃវែង កណ្តាល តាកែវ បន្ទាយមានជ័យ បាត់ដំបង កំពត កំពង់ស្ពឺ ព្រះវិហារ និងខេត្តស្វាយរៀង ។

## ខ-ការងារតាមជំនាញដទៃទៀត

### ខ.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារសរុប ៨២ ក្នុងនោះ ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ០៣ ច្រកទ្វារកំពង់ផែអន្តរជាតិ ០៣ ច្រកទ្វារព្រំដែនអន្តរជាតិ ២៦ ច្រកទ្វារព្រំដែនទ្វេភាគី ១៤ ច្រកទ្វារតំបន់ព្រំដែន ២៦ និងច្រកទ្វារកំពង់ផែសមុទ្រ ១០ ។

គិតពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋបានចំនួន ៨៨១ក្បាល ។

### ខ.២-ការងារវិនិយោគ អភិវឌ្ឍ និងអន្តរវិស័យ

ក្នុងរយៈពេល ០៩ខែ ឆ្នាំ២០២១ នេះ ក្រសួងមហាផ្ទៃបានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍរយៈពេល ០៥ឆ្នាំ (២០២០-២០២៤) អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកណ្តាល ព្រះសីហនុ និងខេត្តស្វាយរៀង និងគម្រោងអភិវឌ្ឍឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្តចំនួន ១០ ស្មើ ១០២គម្រោង ទឹកប្រាក់សរុបចំនួន ៤៥៨.៧១១.១៣១.២៦០រៀល រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ចាម ព្រះសីហនុ កែប កំពត ព្រះវិហារ កំពង់ស្ពឺ បន្ទាយមានជ័យ សៀមរាប និងខេត្តកណ្តាល និងគម្រោងអភិវឌ្ឍឆ្នាំ២០២១ របស់រដ្ឋបាលរាជធានី ខេត្តចំនួន ១៣

ស្មើ ៨៥គម្រោង ទឹកប្រាក់សរុបចំនួន ២២៤.៥៣៣.៦១០.៧០០រៀល រួមមាន រាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រះសីហនុ តាកែវ ក្រចេះ បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ កំពត ព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ធំ។

ទន្ទឹមនេះ ក្រសួងក៏បាន និងកំពុងពិនិត្យ សិក្សាលើសំណើផ្សេងៗពាក់ព័ន្ធនឹងការវិនិយោគ និងអភិវឌ្ឍ នៅក្នុងរាជធានី ខេត្តមួយចំនួនទៀតផងដែរ ។

**ខ.៣-ការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ**

បានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១៧ (សមាគម ៦៩ និងអង្គការមិនមែនរដ្ឋាភិបាល ៤៨) ។ គិតមកដល់បច្ចុប្បន្ន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃសរុបចំនួន ៦.០១៩ (សមាគម ២.៤៤៨ អង្គការមិនមែនរដ្ឋាភិបាល ៣.៤១៩ និងសហគមន៍ជនជាតិដើមភាគតិច ១៥២)។ <u>កត់សម្គាល់</u> ៖ បានសម្រេចលុបឈ្មោះចេញពីបញ្ជីចំនួន ១២ (សមាគម ០៤ និងអង្គការមិនមែនរដ្ឋាភិបាល ០៨) ។

ចំពោះគណបក្សនយោបាយ គិតមកដល់បច្ចុប្បន្នសរុបមានចំនួន ៤៧គណបក្ស ក្នុងនោះ គណបក្សនយោបាយដែលបានចុះបញ្ជីមានចំនួន ៤៤គណបក្ស ។ <u>កត់សម្គាល់</u> ៖ ក្រសួងបានសម្រេចអនុញ្ញាតឱ្យបង្កើតគណបក្សនយោបាយចំនួន ០១ និងលុបឈ្មោះចេញពីបញ្ជីចំនួន ០៤ ។

## ៣-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ (ធ្វេមាស គិតពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១)

### ក-សភាពការណ៍សន្តិសុខ និងលទ្ធផលកិច្ចប្រតិបត្តិការ

#### ក.១-សភាពការណ៍អន្តរជាតិ ដែលជះឥទ្ធិពលដល់សន្តិសុខជាតិ

ក្នុងរយៈពេល ០៩ខែនេះ ស្ថានការណ៍សន្តិសុខក្នុងពិភពលោកមានសភាពកាន់តែតានតឹង និងស្មុគស្មាញ ជាមួយនឹងការប្រែប្រួលយ៉ាងឆាប់រហ័ស បង្កឱ្យមានហានិភ័យនៅគ្រប់តំបន់ ក្នុងនោះអធិករណ៍ដែលជាប្រធានបទក្តៅ មានជាអាទិ៍ ៖ វិវាទកិច្ចព្រមព្រៀងអាវុធនុយក្លេអ៊ែរ ការរត់ប្រណាំងបច្ចេកវិទ្យាសព្វាវុធ សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា ជម្លោះបូរណភាពទឹកដី ដែនសមុទ្រ ដែនកោះ សង្គ្រាមស៊ីវិលនៃជម្លោះមនោគមន៍វិជ្ជាសាសនា ការប្រែប្រួលអាកាសធាតុ ការឆ្លងរាតត្បាតជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មី និងជាពិសេសការទប់ស្កាត់និន្នាការពហុប៉ូល តាមរយៈការប្រឹងប្រែងបង្ហាញអំពីឧត្តមភាពយោធា និងការពង្រឹងយុទ្ធសាស្ត្រ ដើម្បីក្តោបក្តាប់ភូមិសាស្ត្រនយោបាយ-សេដ្ឋកិច្ចរបស់ប្រទេសមហាអំណាចធំៗ ដែលបាន និងកំពុងស្តែងឡើងយ៉ាងស្រួចស្រាល់ ហើយជះឥទ្ធិពលអវិជ្ជមានគួរឱ្យព្រួយបារម្ភដល់សន្តិសុខក្នុងតំបន់ និងសកលលោក ។

ដោយឡែកនៅក្នុងតំបន់ ៖ ក្រោយរបបយោធាធ្វើរដ្ឋប្រហារទម្លាក់រដ្ឋាភិបាលស៊ីវិល ចលនាតស៊ូប្រឆាំងបានផ្ទុះឡើងពាសពេញប្រទេសមីយ៉ាន់ម៉ា ហើយកំពុងធ្លាក់ក្នុងស្ថានភាពមួយដែលអាចនឹងមានការវាយប្រហារគ្នាជាទ្រង់ទ្រាយធំកើតឡើង និងក្លាយជាសង្គ្រាមស៊ីវិលអូសបន្លាយរយៈពេលយូរ ។ រីឯវិបត្តិនយោបាយប្រទេសថៃក៏ពុំទាន់រកឃើញដំណោះស្រាយល្អនៅឡើយ ការប្រមូលផ្តុំធ្វើបាតុកម្មបណ្តេញនាយករដ្ឋមន្ត្រីចុះចេញពីតំណែងនៅតែបន្តកើតមាន ។

#### ក.២-សភាពការណ៍សន្តិសុខផ្ទៃក្នុង និងតំបន់ព្រំដែន

##### ក.២.១-សភាពការណ៍សន្តិសុខផ្ទៃក្នុង

ជារួម បើទោះបីជាស្ថិតក្រោមឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ជាមួយនឹងការវិវត្តប្រែប្រួលនៃសភាពការណ៍សន្តិសុខសកល រួមទាំងការប្រឈមទៅនឹងការប៉ុនប៉ងបង្កភាពចលាចលក្នុងសង្គម បំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុងជាតិ តាមរយៈការអនុវត្តយុទ្ធសាស្ត្រចាស់-ថ្មី ក៏ដូចជាឧបាយកលសកម្មភាពឧទ្ទាមកម្មរបស់ក្រុមឧទ្ទាមទាំង

ក្នុង និងក្រៅប្រទេសយ៉ាងណាក្តី ក៏កម្ពុជាយើងនៅតែបន្តរក្សាបានយ៉ាងល្អប្រសើរនូវប្រក្រតីភាពនៃគ្រប់សកម្មភាពក្នុងសង្គមទាំងមូល ។

ស្ថាប័នកំពូលទាំង៣ របស់ជាតិ ព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ និងបណ្តាគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌... ព្រមទាំងព្រឹត្តិការណ៍នយោបាយនានា ត្រូវបានធានាការពារយ៉ាងគត់មត់ កម្មវិធីជាតិ និងអន្តរជាតិចំនួន ៨.៤៦៩លើក និងសកម្មភាពបាតុកម្ម កូដកម្ម ១៣៨លើក ត្រូវបានធានាសណ្តាប់ធ្នាប់ និងដំណើរការដោយរលូន ។ <u>**កត់សម្គាល់ ៖**</u> កម្ពុជានៅតែបញ្ចៀសបាននូវហានិភ័យដែលបង្កឡើងដោយអំពើភេរវកម្ម ខណៈប្រទេសទាំងក្នុង និងក្រៅតំបន់ កំពុងទទួលរងនូវការវាយប្រហារដោយអំពើនេះ យ៉ាងសាហាវយង់ឃ្នងចំនួន ១.១៨១លើក ក្នុង ៥០ប្រទេស (ស្លាប់ ៤.៥៧០នាក់ របួស ៣.៦៨១នាក់) និងទប់ស្កាត់ចលនាបដិវត្តន៍ពណ៌មិនឱ្យកើតមានសារជាថ្មី ។ *កងកម្លាំងនគរបាលជាតិបានធ្វើពលិកម្មយ៉ាងធំធេងនៅក្នុងបេសកកម្មខាងលើនេះ ដោយដៃម្ខាងខិតខំប្រឹងប្រែងរក្សា ការពារស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពក្នុងសង្គម និងបូរណភាពទឹកដីផង និងដៃម្ខាងចូលរួម សហការជាមួយគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គ្រប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តវិធានការនានាក្នុងការទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ផង ។*

### ក.២.២-សភាពការណ៍តំបន់ព្រំដែន

-ព្រំដែនកម្ពុជា-ថៃ ៖ ភាគីថៃបង្កសកម្មភាពមិនប្រក្រតីចំនួន ១០លើក (មានដូចជា ចូលមកធ្វើស្រែនៅតំបន់បង្គោលលេខ៤៣ ចូលមកដាំដើមឈើនៅតំបន់មិនទាន់កំណត់បង្គោលព្រំដែន ហាមប្រជាពលរដ្ឋខ្មែរមិនឱ្យប្រើប្រាស់ទឹកអណ្តូងនៅភូមិសាស្ត្រអានសេះ ខេត្តព្រះវិហារ...) ។

-ព្រំដែនកម្ពុជា-វៀតណាម៖ ភាគីវៀតណាមបង្កសកម្មភាពមិនប្រក្រតីចំនួន ០៧លើក (មានដូចជាបន្តបោះតង់ និងសង់រោងបន្ថែមនៅតាមខ្សែបន្ទាត់ព្រំដែន ក្រោមហេតុផលធ្វើប៉ុស្តិ៍សង្កេតការណ៍ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដែលមកដល់ពេលនេះ មានចំនួន ៣៦៤តង់/០៩ខេត្ត ក្នុងនោះ រុះរើចេញវិញចំនួន ១០១តង់ ឈូសឆាយដីធ្វើផ្លូវទល់មុខភូមិសាស្ត្រ X16 ជិតបង្គោលព្រំដែនលេខ៩៩ ក្នុងខេត្តត្បូងឃ្មុំ ចូលមកកាប់ឆ្ការព្រៃធ្វើចំការនៅតំបន់មិនទាន់ឯកភាពគ្នា ក្នុងខេត្តរតនគិរី...) ។

-ព្រំដែនកម្ពុជា-ឡាវ ៖ ភាគីឡាវបង្កសកម្មភាពមិនប្រក្រតីចំនួន ០៤លើក (មានដូចជា យោធាឡាវឈូសឆាយដីធ្វើផ្លូវនៅតំបន់មិនទាន់បោះបង្គោលព្រំដែន ចន្លោះបង្គោលព្រំដែនលេខ ០៣៣-០៣៤ ពីអ័ក្សផ្លូវជាតិលេខ៧ ក្នុងខេត្តស្ទឹងត្រែង...) ។

ក្នុងការផ្លាស់ប្តូរព័ត៌មានសភាពការណ៍តាមបន្ទាត់ព្រំដែន ក៏ដូចជាការដោះស្រាយបាតុភាពខាងលើ និងការទប់ស្កាត់បទល្មើសផ្សេងៗទៀត ភាគីកម្ពុជាបានជួបប្រជុំជាមួយភាគីថៃចំនួន ៨៨លើក ភាគីវៀតណាម ៤៦លើក និងភាគីឡាវ ០៣លើក ។

ដោយឡែក កម្លាំងនគរបាលដែលបានរៀបចំដាក់ឱ្យនៅប្រចាំការតាមគោលដៅនៃខេត្តមានព្រំប្រទល់ជាប់ជាមួយប្រទេសថៃ និងវៀតណាម បានបន្តយកចិត្តទុកដាក់សម្របសម្រួលដល់ការអនុវត្តវិធានសុខាភិបាលចំពោះអ្នកដែលឆ្លងកាត់ព្រំដែន ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលទៅក្នុងសហគមន៍ ។ <u>**កត់សម្គាល់ ៖**</u> បានធ្វើការត្រួតពិនិត្យ និងបង្ក្រាបសកម្មភាពមេខ្យល់ដែលនាំពលករចេញចូល-ឆ្លងដែនខុសច្បាប់ និងគេចវេសពីការធ្វើចត្តាឡីស័ក (គិតពីថ្ងៃទី១៣ ខែកុម្ភៈ ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១) ចំនួន ១៨៤ករណី ឃាត់ខ្លួន ២៩៣នាក់ ស្រី ១៨នាក់ និងពលករចំនួន ១១.៩៨៩នាក់ ស្រី ៣.៩៥៥នាក់ ។

## ខ-សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ

### ខ.១-សភាពការណ៍ និងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ

បទល្មើសរួមកើតឡើង ២.២០៩/២.៤១៨លើក ថយ ២០៩លើក ស្មើ ៩% (បទឧក្រិដ្ឋ ៤២២/៤៩១លើក ថយ ៦៩លើក និងបទមជ្ឈិម ១.៧៨៧/១.៩២៧លើក ថយ ១៤០លើក) ស្លាប់ ១៦៣នាក់ របួស ៧០៧នាក់ រងគ្រោះ ១.១២២នាក់ បាត់ម៉ូតូ ២៤៥គ្រឿង រថយន្ត ១៨គ្រឿង និងសម្ភារៈ មាសប្រាក់មួយចំនួនទៀត ។ កត់សម្គាល់៖ បទល្មើសដែលមានការកើនឡើង រួមមាន៖ រំលោភសេពសន្ថវៈ រំលោភសម្លាប់ អំពើហិង្សាក្នុងគ្រួសារ និងបំពានខាងផ្លូវភេទដទៃទៀត ។

បង្ក្រាបរួមបាន ២.០៤៩ករណី ស្មើ ៩៣% ឃាត់ខ្លួន ២.៩២៥នាក់ (បទឧក្រិដ្ឋ ៣៨៦ករណី/៥៦៩នាក់ និងបទមជ្ឈិម ១.៦៦៣ករណី/២.៣៥៦នាក់) ក្នុងនោះ បង្ក្រាបជាក់ស្តែង ១.៦៤០ករណី ស្មើ ៨០% ឃាត់ខ្លួន ២.២៧០នាក់ និងបង្ក្រាបដោយស៊ើបអង្កេត ៤០៩ករណី ស្មើ ២០% ឃាត់ខ្លួន ៦៥៥នាក់។ ក្រៅពីនេះ បានអនុវត្តដីកា ៣៩ដីកា/៣៩នាក់ (បទឧក្រិដ្ឋ ០៧ដីកា/០៧នាក់ និងបទមជ្ឈិម ៣២ដីកា/៣២នាក់)។ រឹបអូសវត្ថុតាងបាន ៖ អាវុធវែង ០៥ដើម អាវុធខ្លី ២២ដើម អាវុធកែច្នៃ ០៧ដើម កាំបិត-ដាវ ១១៥ដើម ម៉ូតូ ៤២៩ គ្រឿង រថយន្ត ៣៣ គ្រឿង និងសម្ភារៈ មាសប្រាក់មួយចំនួន ។ ជនល្មើស និងវត្ថុតាងត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

<u>កត់សម្គាល់</u> ៖ ក្នុងចំណោមជនសង្ស័យដែលបានឃាត់ខ្លួន ២.៩២៥នាក់ ពិនិត្យឃើញមានផ្ទុកសារធាតុញៀន ១.១០១នាក់ ស្មើ ៣៨%។ ដោយឡែក បង្ក្រាបដោយស៊ើបអង្កេតបណ្តាករណីកើតមុនរយៈពេល ០៧ករណី ឃាត់ខ្លួន ១០នាក់ និងបានអនុវត្តដីកាឆ្នាំចាស់ ២៤៥ដីកា/២៤៤នាក់ (បទឧក្រិដ្ឋ ៥២ដីកា/៥២នាក់ និងបទមជ្ឈិម ១៩៣ដីកា/១៩២នាក់) ។

### ខ.២-ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

បង្ក្រាបរួម ៤.៤២០ករណី ឃាត់ខ្លួន ៩.៤៦៨នាក់ (ស្រី ៥១៦នាក់) ជនបរទេស ១៦៧នាក់/១៤សញ្ជាតិ និងអនុវត្តដីកា ២៩៩ដីកា ឃាត់ខ្លួន ៣៥៤នាក់ ។ រឹបអូសវត្ថុតាងបាន៖ គ្រឿងញៀនសរុបចំនួន ១.១៤៤,៧៨១ គ.ក្រ សារធាតុគីមីផ្សំជាង ១តោន ដើមកញ្ឆា ៨៧.៩៧១ដើម កញ្ឆាក្រៀម ១០៣,៣៦៩គ.ក្រ អាវុធវែង ០៣ដើម អាវុធខ្លី ១៤ដើម ម៉ូតូ ១.២៦១គ្រឿង រថយន្ត ៨៤គ្រឿង ទូរស័ព្ទដៃ ៤.០៤២គ្រឿង ជញ្ជីង ២៣៥គ្រឿង និង ឧបករណ៍វេចខ្ចប់គ្រឿងញៀនមួយចំនួន ។ វត្ថុតាង និងជនល្មើសត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

### ខ.៣-ការងារប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

បង្ក្រាបរួម ២២៦ករណី ឃាត់ខ្លួន ៣៣៤នាក់ (ស្រី ៣៣នាក់) ជនបរទេស ០៤នាក់ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត និងរំដោះជនរងគ្រោះបាន ៧៦២នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៣២នាក់ និងអាណាព្យាបាល ៧៣០នាក់) ក្នុងនោះ អំពើជួញដូរមនុស្ស ១៤៧ករណី ឃាត់ខ្លួន ២៤៨នាក់ (ស្រី ២៥នាក់) ជនបរទេស ០៣នាក់ រំដោះជនរងគ្រោះបាន ៦៤៩នាក់ និងអាជីវកម្មផ្លូវភេទ ៧៩ករណី ឃាត់ខ្លួន ៨៦នាក់ (ស្រី ០៨នាក់) ជនបរទេស ០១នាក់ និងរំដោះជនរងគ្រោះបាន ១១៣នាក់ ។

### ខ.៤-ការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបក្រុមក្មេងទំនើង

បង្ក្រាបបាន ៨៣១ករណី ឃាត់ខ្លួន ១.៩៣៣នាក់ (ស្រី ៦១នាក់) ក្នុងនោះ អនុវត្តវិធានការច្បាប់ ៤៥៣ករណី ឃាត់ខ្លួន ៧៨២នាក់ ស្រី ១២នាក់ (បទល្មើសព្រហ្មទណ្ឌ ១៦៦ករណី ឃាត់ខ្លួន ៣៣៦នាក់ ស្រី ០៥នាក់

និងបទល្មើសគ្រឿងញៀន ២៨៧ករណី ឃាត់ខ្លួន ៤៤៦នាក់ ស្រី ០៧នាក់) កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត និងអនុវត្តវិធានការរដ្ឋបាល ៣៧៨ករណី ឃាត់ខ្លួន ១.១៥១នាក់ ស្រី ៤៩នាក់ ។

**ខ.៥-ការងារបង្ក្រាបល្បែងស៊ីសង**

បង្ក្រាបបាន ១.១៤៤ករណី ឃាត់ខ្លួន ៣.១៨៧នាក់ (ស្រី ១.៤៤០នាក់) រួមទាំងវត្ថុតាង ៖ រថយន្ត ២៤ គ្រឿង ម៉ូតូ ៣៣៥គ្រឿង កុំព្យូទ័រ ២១គ្រឿង... ក្នុងនោះ អនុវត្តវិធានការរដ្ឋបាល ៩៨៧ករណី ឃាត់ខ្លួន ២.៦៤៨ នាក់ (ស្រី ១.៣១២នាក់) និងអនុវត្តវិធានការច្បាប់ ១៥៧ករណី ឃាត់ខ្លួន ៥៣៩នាក់ (ស្រី ១២៨នាក់) កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

**ខ.៦-ការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច**

បង្ក្រាបរួម ២៥៧លើក (សហការបង្ក្រាប ២១២លើក) ឃាត់ខ្លួនជនសង្ស័យ ១០៥នាក់ (ជនជាតិចិន ០២នាក់) ក្នុងនោះ បញ្ជូនទៅសាលាដំបូងខេត្ត ២៣នាក់ បញ្ជូនទៅស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធ ៥៨នាក់ និងធ្វើកិច្ចសន្យាអប់រំ ២៤នាក់ (ជនជាតិចិន ០២នាក់)។ **កត់សម្គាល់ ៖** ភាគច្រើនជាបទល្មើសព្រៃឈើ ជលផល កម្មសិទ្ធិបញ្ញា ឱសថក្លែងក្លាយ ការនាំចូលទំនិញគេចពន្ធ អាហារខូចគុណភាព ...។

**គ-សភាពការណ៍សណ្តាប់ធ្នាប់សាធារណៈ**

គ្រោះថ្នាក់សង្គមកើតឡើង ៥.៣៥៩/៦.០៥៦លើក ថយ ៦៩៧លើក ស្មើ ១២% (ស្លាប់ ៣.៦៤១នាក់ របួស ៣.៦៣២នាក់) ក្នុងនោះ គ្រោះថ្នាក់ចរាចរណ៍ ១.៩២៧/២.៤៦៨លើក ថយ ៥៤១លើក ស្មើ ២២% (ស្លាប់ ១.០៦៩ នាក់ របួស ២.៦៧៣នាក់) អាវុធជាតិផ្ទុះ ២៦លើក (ស្លាប់ ០៨នាក់ របួស ២២នាក់) អគ្គិភ័យ ៤៩០លើក (ស្លាប់ ១៩នាក់ របួស ១៩នាក់ ឆេះតូប ២៣១តូប ឆេះផ្ទះ ៣៥១ខ្នង) ខ្យល់ព្យុះ ៣៨៣លើក (ស្លាប់ ០៦នាក់ របួស ៣១ នាក់ របើកដំបូល ៥.១៨៧ខ្នង រលំផ្ទះ ៦៥៤ខ្នង) រន្ទះបាញ់ ៩០លើក (ស្លាប់ ៧៤នាក់ របួស ៤៥នាក់) អត្តឃាត ៧០០លើក (ស្លាប់ ៧០០នាក់ របួស ០៦នាក់) និងគ្រោះថ្នាក់ផ្សេងៗ ១.៧៣៨លើក (ស្លាប់ ១.៧៦៥នាក់ របួស ៤៧១នាក់) ។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើនេះ ក្រសួងមហាផ្ទៃបានប្រមូលផ្តុំចាត់វិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះ ដូចខាងក្រោម ៖

**-ការងារចរាចរណ៍** ៖ បន្តពង្រឹងយន្តការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកជាប្រចាំ ដើរទន្ទឹមនឹងការខិតខំផ្សព្វផ្សាយអប់រំផង និងការកសាងបន្ថែមនូវច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធផង ។ គិតពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ បានត្រួតពិនិត្យរកឃើញយានយន្តល្មើស និងផាកពិន័យសរុបចំនួន ១៥១.៦៣៧គ្រឿង (ក្នុងនោះ រថយន្ត ៤៣.០២៦គ្រឿង) ។

**-ការងារអគ្គិភ័យ៖** បន្តពង្រឹងកិច្ចប្រតិបត្តិការជួយសង្គ្រោះក្នុងហេតុការណ៍អគ្គិភ័យ ព្រមជាមួយនឹងការជំរុញការផ្សព្វផ្សាយអប់រំ លើកកម្ពស់ការប្រុងប្រយ័ត្ន និងការអនុវត្តវិធានការនៃការបង្ការ ទប់ស្កាត់អគ្គិភ័យជាប់ជាប្រចាំ។

**-ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ** ៖ បន្តយកចិត្តទុកដាក់ពង្រឹងជាប្រចាំ ទាំងលើការត្រួតពិនិត្យ ការចុះបញ្ជីគ្រប់គ្រង និងការផ្សព្វផ្សាយអប់រំ។ ជាក់ស្តែង បានផ្តល់ប័ណ្ណប្រើប្រាស់អាវុធថ្មីចំនួន ១.៣៤៧ប័ណ្ណ (ខ្លី ១.០៤៣ ប័ណ្ណ វែង ៣០៤ប័ណ្ណ) ប្តូរប័ណ្ណប្រើប្រាស់អាវុធចំនួន ៣.០៩៨ប័ណ្ណ (ខ្លី ២.៧៥០ប័ណ្ណ វែង ៣៤៨ប័ណ្ណ)។ តាមរយៈព័ត៌មានដែលផ្តល់ដោយប្រជាពលរដ្ឋ ក្រសួងបានសហការជាមួយក្រុមប្រតិបត្តិការកំចាត់មីន ចុះប្រមូល និងបំផ្លាញចោលនូវគ្រាប់គ្រប់ប្រភេទចំនួន ១៦.៧០៨គ្រាប់ ។ ទន្ទឹមនេះ ក៏បានប្រមូលយកអាវុធដែលប្រជាពលរដ្ឋ ដោយស្ម័គ្រចិត្តប្រគល់ជូនចំនួន ១៤៨ដើម ផងដែរ ។

-**ការងារនគរបាលបេតិកភណ្ឌ** ៖ បានចូលរួមយ៉ាងសកម្មក្នុងការថែរក្សាសម្បត្តិបេតិកភណ្ឌជាតិឱ្យគង់វង្ស តាមរយៈការពង្រឹងការងារទប់ស្កាត់ការលួចជីកគាស់កាយប្រាសាទបុរាណ និងរមណីយដ្ឋានបុរេប្រវត្តិសំខាន់ៗ និងសហការការពារបណ្ដាគោលដៅនៃដំណើរការជួសជុល និងរក្សាទុកសម្បត្តិវប្បធម៌ជាតិនានារបស់អាជ្ញាធរមានសមត្ថកិច្ច ។ ទន្ទឹមនេះ នគរបាលបេតិកភណ្ឌក៏បាន និងកំពុងរៀបចំបញ្ចូលទិន្នន័យសារពើភណ្ឌបេតិកភណ្ឌទៅក្នុងប្រព័ន្ធកុំព្យូទ័រផងដែរ ដើម្បីបង្កភាពងាយស្រួលដល់គ្រប់តម្រូវការការងារដែលពាក់ព័ន្ធ ។

### ៤-ការងារអត្តសញ្ញាណកម្ម

#### ក-ការងារអត្រានុកូលដ្ឋាន

-គិតពីខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋបានចំនួន ១៩.៨៩១.២០៥នាក់ ស្រី ៩.៨៨៦.៦៥៤នាក់។ <u>កត់សម្គាល់៖</u> ក្នុងរយៈពេល ០៩ខែនេះ ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ៣៣៨.២០៤បញ្ជី ស្មើ ៣៩១.៤៩៧នាក់ ស្រី ១៩១.៧៧២នាក់ ចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទបាន ៩១៧ច្បាប់ ស្មើ ៤.៩៥៤សន្លឹក ចេញសេចក្ដីសម្រេច ស្ដីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបាន ៥.១៧១ច្បាប់ កែតម្រូវបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមសេចក្ដីសម្រេចបាន ២.៧០៧ច្បាប់ និងទទួលសាលក្រម និងដីកាកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានចំនួន ៥៩៧ច្បាប់ ពីបណ្ដាសាលាដំបូងរាជធានី ខេត្តចំនួន ២៣ ។

-គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ វាយបញ្ចូលទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានកំណើតទៅក្នុងប្រព័ន្ធ បានចំនួន ៦.៤៨៥.៥០៥បញ្ជី ។

-បានចេញសេចក្ដីសម្រេចស្ដីពី ការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសចំនួន ៤២៣ច្បាប់ រួមមាន ១៩សញ្ជាតិ ។

-បើកផ្ដល់ជូនរដ្ឋបាលរាជធានី ខេត្ត ទាំង ២៥ នូវសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ១៨.២៦៨ក្បាល និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ២.១៤០.៥០០សន្លឹក ។

#### ខ-ការងារគ្រប់គ្រងការស្នាក់នៅ

-គិតមកដល់បច្ចុប្បន្ន ទិន្នន័យប្រជាពលរដ្ឋដែលបានចុះបញ្ជីស្ថិតិសរុបមានចំនួន ១៦.០៤២.៤០៦នាក់ ស្រី ៨.១៩៥.៨៩៦នាក់ ។

-ការបញ្ចូលទិន្នន័យស្ថិតិប្រជាពលរដ្ឋក្នុងប្រព័ន្ធកុំព្យូទ័រនៅខេត្តកែប និងខេត្តកំពត រួមមាន សៀវភៅស្នាក់នៅបានចំនួន ៩៦៥គ្រួសារ ស្មើ ៣.៩០៤នាក់ ស្រី ១.៩៨៧នាក់ សៀវភៅគ្រួសារបានចំនួន ៧៦៥គ្រួសារ ស្មើ ៣.១៨៩នាក់ ស្រី ១.៦២៥នាក់ ។ សរុបជារួម បញ្ចូលទិន្នន័យសៀវភៅស្នាក់នៅបានចំនួន ៣.៧៥១គ្រួសារ ស្មើ ១៤.៨៣១នាក់ ស្រី ៧.៥៥៣នាក់ និងសៀវភៅគ្រួសារបានចំនួន ៣.១៥៣គ្រួសារ ស្មើ ១៣.០០៦នាក់ ស្រី ៦.៧៧៩នាក់ ។

-បើកផ្ដល់ជូនប្រជាពលរដ្ឋនូវសៀវភៅស្នាក់នៅថ្មីបានចំនួន ៦១.៨៨៣ក្បាល ទុតិយតា ៤៥.៩៤៥ក្បាល និងសៀវភៅគ្រួសារថ្មីបានចំនួន ៥០.៨៧៨ក្បាល ទុតិយតា ៣០.៦៥៣ក្បាល។ គិតជារួម ផ្ដល់សៀវភៅស្នាក់នៅបានចំនួន ៣.៤០៧.៤៨៦ក្បាល ទុតិយតា ៤០២.២៨៤ក្បាល និងសៀវភៅគ្រួសារបានចំនួន ៣.១០៩.៧២៦ក្បាល ទុតិយតា ២៤៣.៤៧៧ក្បាល ។

-បើកផ្ដល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ទាំង២៥ នូវសៀវភៅស្នាក់នៅចំនួន ១២១.៥០០ក្បាល និងសៀវភៅគ្រួសារចំនួន ១០៧.៨០០ក្បាល ។

ដោយឡែក ចំពោះការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក ពុំមានសកម្មភាពឡើយ ។ កត់សម្គាល់ ៖ គិតចាប់ពីឆ្នាំ២០០២ មកដល់បច្ចុប្បន្ន ពលរដ្ឋខ្មែរដែលធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិក មានចំនួន ២៥១លើក ស្មើ ៧៧៤នាក់ ស្រី ១៩នាក់ ។

**គ-ការងារផ្តល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**

-បោះពុម្ពលិខិតឆ្លងដែន និងផ្តល់ជូនប្រជាពលរដ្ឋបានចំនួន ១៧.៥២១ក្បាល (ជនបរទេសចូលសញ្ជាតិខ្មែរ ១៩៥នាក់) និងបោះពុម្ពលិខិតធ្វើដំណើរជូនពលករកម្ពុជាធ្វើការនៅបរទេសបានចំនួន ៩.៦៣៥ក្បាល ។

-ទទួលទិន្នន័យស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីសរុបចំនួន ២៤៥.៤៤៨នាក់ (ទិន្នន័យបានការ ២៣២.៥៦២នាក់ ស្នួនខ្មៅដៃ-ខូច ១២.៨៨៦នាក់) និងទទួលពាក្យសុំកែតម្រូវ បោះពុម្ពឡើងវិញនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតាចំនួន ៥៥.២៨៨សន្លឹក ។

-ជារួម បោះពុម្ពអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (គិតទាំងទិន្នន័យថ្មី និងទិន្នន័យទុតិយតា) សរុបបានចំនួន ៣៧៣.៧៤៨សន្លឹក និងផ្តល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បានចំនួន ៣៣៣.៧៤៩សន្លឹក ។ ដោះស្រាយករណីស្នួនខ្មៅដៃជូនប្រជាពលរដ្ឋបានចំនួន ៣៩៦.៩៦១ករណី នៅសល់ ២.៩៣០ករណី ។

កត់សម្គាល់៖ ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋនៅស្នាក់ការផ្សារទំនើបអ៊ីអនម៉ល២ បានចំនួន ៦.៣៩៣នាក់ និងនៅនាយកដ្ឋានបានចំនួន ៣.៨៥៨នាក់ (ជនបរទេសចូលសញ្ជាតិខ្មែរ ៩៣នាក់) ។

**ឃ-ការងារសញ្ជាតិ**

-បានអនុវត្តនីតិវិធីលើករណីសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មចំនួន ១២៣ករណី ស្មើ ១២៤នាក់ ស្រី ១២នាក់ មាន ១២សញ្ជាតិ ដោយអាពាហ៍ពិពាហ៍ ០២ករណី ស្មើ ០៤នាក់ ស្រី ០២នាក់ មាន ០២សញ្ជាតិ និងករណីលះបង់សញ្ជាតិចំនួន ២២ករណី ស្មើ ២៣នាក់ ស្រី ១៣នាក់ ។

-ទទួលព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មចំនួន ២៣៥នាក់ អាពាហ៍ពិពាហ៍ ០៣នាក់ (ស្រី) និងព្រះរាជក្រឹត្យអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរចំនួន ២៦នាក់ ស្រី ១៤នាក់ ។

-គិតពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ន ជនបរទេសសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មសម្រេចបានចំនួន ២.២៦៧ករណី ស្មើ ២.៣២៧នាក់ មាន ៥០សញ្ជាតិ ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ១០០នាក់ មាន ៣២សញ្ជាតិ និងលះបង់សញ្ជាតិខ្មែរចំនួន ១៨៨នាក់ ។

**ង-ការងារពង្រឹងយន្តការផ្តល់សេវាអត្តសញ្ញាណកម្ម**

-ឆ្លើយតប និងដោះស្រាយសំណូមពរជូនប្រជាពលរដ្ឋ តាមរយៈក្រុមការងារសេវាអត្តសញ្ញាណកម្ម និងប្រតិកម្មរហ័ស បានចំនួន ២.៦៧២ករណី (ការងារអត្រានុកូលដ្ឋាន ៩០១ករណី ការងារស្ថិតិប្រជាពលរដ្ឋ ១៧០ករណី ការងារលិខិតឆ្លងដែន ៨៦ករណី និងការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ១.៥១៥ករណី) ។

-ដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាលអត្តសញ្ញាណកម្មកំណែទី២ (GDI IDC) លើ Web និង Mobile Application និងកម្មវិធីព័ត៌មានអត្តសញ្ញាណកម្ម (GDI Info) សម្រាប់ប្រើប្រាស់លើទូរស័ព្ទដៃស្មាតហ្វូន (Android និងIOS) ។

-បានធ្វើការកែសម្រួលសេចក្តីណែនាំលេខ ០០២សណន ស្តីពីការចុះបញ្ជីអត្តសញ្ញាណកម្មតាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅថ្នាក់ឃុំ សង្កាត់ ។

-បាន និងកំពុងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបែងចែកទិន្នន័យអត្តសញ្ញាណកម្មតាមថ្នាលព័ត៌មានវិទ្យាសម្រាប់ប្រព័ន្ធចុះបញ្ជីអាជីវកម្មបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធផ្សេងទៀតនាពេលខាងមុខ។

-គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនដែលបានចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDx មានចំនួន ៨.១៥៣ក្រុមហ៊ុន ។

**ច-វឌ្ឍនភាពនៃការផ្តល់ឯកសាររដ្ឋបាលកម្ពុជាឱ្យសហព័ន្ធជាខ្មែរ គុន និងជនបរទេសអន្តោប្រវេសន្ត**

-អនុវត្តនីតិវិធីលើករណីស្នើសុំឯកសារអត្រានុកូលដ្ឋានឡើងវិញ មកទល់ពេលនេះបានចំនួន ១៦២ច្បាប់។

-ផ្តល់សៀវភៅស្នាក់នៅ (ក២) បានចំនួន ២៦ក្បាល ស្មើ ១៣១នាក់ ស្រី ៧៤នាក់ និងសៀវភៅគ្រួសារ (ក៤) បានចំនួន ០៨ក្បាល ស្មើ ៣៤នាក់ ស្រី ២១នាក់។ គិតជារួម ផ្តល់សៀវភៅស្នាក់នៅបានចំនួន ២៥៦ក្បាល ស្មើ ១.០២៦នាក់ ស្រី ៤៨២នាក់ និងសៀវភៅគ្រួសារបានចំនួន ១០៨ក្បាល ស្មើ ២៧៨នាក់ ស្រី ១៤៦នាក់ ។

-គិតមកដល់បច្ចុប្បន្ន ការអនុវត្តនីតិវិធីលើករណីសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសអន្តោប្រវេសន្តបានចំនួន ០៩ករណី ស្មើ ១៣នាក់ ស្រី ០៧នាក់ មាន ០១សញ្ជាតិ (ស្នាក់នៅជាប់ចាប់ពី ០៧ឆ្នាំ ចំនួន ០៥ករណី ស្មើ ០៩ នាក់ ស្រី ០៤នាក់ និងតាមរយៈអាពាហ៍ពិពាហ៍ចំនួន ០៤ករណី ស្មើ ០៤នាក់ ស្រី ០៣នាក់) ។

**៥-ការងារអន្តោប្រវេសន៍**

**ក-ការងារគ្រប់គ្រងដំណើរចេញ ចូលប្រទេស**

-ជនបរទេសធ្វើដំណើរចូលមកកម្ពុជាជាលក្ខណៈអន្តរជាតិមានចំនួន ១៦៩.៦២៩នាក់/១៥៨សញ្ជាតិ ថយចុះ ៨៩,៥៤% និងចេញពីកម្ពុជាជាលក្ខណៈអន្តរជាតិចំនួន ១៨៨.០៣៣នាក់ ថយចុះ ៨៨,៤១% ។ ដោយឡែក សម្រាប់ដំណើរចេញចូលក្នុងក្របខ័ណ្ឌតំបន់ព្រំដែន គ្មាន ។

<u>កត់សម្គាល់៖</u> ក្រោយពិនិត្យឃើញមានពាក់ព័ន្ធបទល្មើសផ្សេងៗ និងគោលបំណងធ្វើដំណើរមិនច្បាស់លាស់ សមត្ថកិច្ចបានបដិសេធមិនឱ្យចូលប្រទេសចំនួន ៧៥នាក់/៣៣សញ្ជាតិ និងផ្អាកដំណើរចេញពីប្រទេសចំនួន ០៧នាក់/០៣សញ្ជាតិ ។

-ពលរដ្ឋខ្មែរធ្វើដំណើរចេញពីប្រទេសជាលក្ខណៈអន្តរជាតិចំនួន ២៧.៦៣០នាក់ ថយចុះ ៩១,៥៤% ចេញក្របខ័ណ្ឌតំបន់ព្រំដែន ១.៤៨១នាក់ ថយចុះ ៩៩,៩៥% និងចូលមកវិញជាលក្ខណៈអន្តរជាតិចំនួន ២១.៥៨២ នាក់ ថយចុះ ៩៤,៨១% ចូលក្នុងក្របខ័ណ្ឌតំបន់ចំនួន ១.៤៨១នាក់ ថយចុះ ៩៩,៩១%។ ដោយឡែក ពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ (ដោយមូលហេតុស្នាក់នៅ ឬធ្វើការខុសច្បាប់) មានចំនួន ១០.៦៨៧ នាក់ (ថៃ ១០.៣៤៦នាក់ ចិន ២១៧នាក់ ឡាវ ២២នាក់ វៀតណាម ៧០នាក់ កូរ៉េខាងត្បូង ០៥នាក់ អាមេរិក ០៤ នាក់ និងម៉ាឡេស៊ី ២៣នាក់) ។

**ខ-ការងារគ្រប់គ្រងវត្តមានជនបរទេស**

**-ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត**

+គិតមកដល់បច្ចុប្បន្ន បានចេញប្រកាសទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន្តនៅកម្ពុជាសរុបចំនួន ៧២.១៣៤ច្បាប់ ស្មើ ១០៣.៧៣៨នាក់ (ស្រី ៥០.១៩៨នាក់) និងបានចេញប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សរុបចំនួន ៨១.៣៧៤ប័ណ្ណ ស្មើ ៨១.៣៧៤នាក់ (ស្រី ៣៨.៨៨៤នាក់) ។

+បានទទួលពាក្យបណ្តឹងតវ៉ាទាមទារសញ្ជាតិខ្មែរពីជនបរទេស ដែលត្រូវបានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីចំនួន ១២៤ករណី ក្នុងនោះ ដោះស្រាយបានចំនួន ១១២ករណី ។

**-ការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត**

+ផ្តល់ទិដ្ឋាការចូលប្រទេសជូនអាកាសយានិក និងបុគ្គលិក ចំនួន ១.០៦៧នាក់ ថយចុះ ៩៩,៨១% ។

+ផ្តល់ទិដ្ឋាការពិសេសប្រភេទ K ជូនពលរដ្ឋខ្មែររស់នៅក្រៅប្រទេសចំនួន ៣៨៦នាក់ ។

+ផ្តល់ទិដ្ឋាការចេញជូនជនបរទេសចំនួន ៨៣៧នាក់ ថយចុះ ៦៤,៨៩% និងពន្យារទិដ្ឋាការស្នាក់នៅបណ្តោះអាសន្នជូនជនបរទេសចំនួន ២១៥.៧៥៥នាក់ ថយចុះ ១៨,៣២% ។

ដោយឡែក ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ចំនួន ៣៧៤នាក់ បានផាកពិន័យគិតជាប្រាក់សរុបចំនួន ២៥៩.៦៩០ដុល្លារ បង់ចូលថវិកាជាតិ ។

**-ការងារគ្រប់គ្រងក្រុមហ៊ុនវិនិយោគ និងពលករបរទេស៖** គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC មានចំនួនសរុប ២.៩៣៥ក្រុមហ៊ុន (ធៀបតួលេខឆ្នាំ២០២០ កើន ៧០ក្រុមហ៊ុន) មានទុនវិនិយោគសរុបចំនួន ៦៩៩.៥៣៧.៧១៤លានដុល្លារ និងផ្តល់ការងារដល់ពលករបរទេស-ខ្មែរ សរុបជាង ៣៥.៥៧៤កន្លែង ក្នុងនោះរួមមាន វិស័យកសិកម្ម ២៥៣ក្រុមហ៊ុន/១៩សញ្ជាតិ វិស័យទេសចរណ៍ ១២៦ក្រុមហ៊ុន/១៧សញ្ជាតិ វិស័យហេដ្ឋារចនាសម្ព័ន្ធ ១៦១ក្រុមហ៊ុន/១៧សញ្ជាតិ និងវិស័យរោងចក្រ-សហគ្រាស ២.៣៩៥ក្រុមហ៊ុន/៤២សញ្ជាតិ ។

**-ការងារគ្រប់គ្រងជនភៀសខ្លួន ៖** គិតមកដល់បច្ចុប្បន្ន ជនបរទេសដែលទទួលបានឋានៈជាជនភៀសខ្លួនមានចំនួន ៦៤នាក់ ស្រី ១៥នាក់ មាន ០៨សញ្ជាតិ អ្នកសុំសិទ្ធិជ្រកកោនចំនួន ២១នាក់ ស្រី ១១នាក់ មាន ០៦សញ្ជាតិ និងជនជាតិម៉ុងតាញ៉ាដែលមិនទាន់បានឋានៈជាជនភៀសខ្លួននៅកម្ពុជាចំនួន ១២នាក់ ស្រី ០២នាក់ ។

**គ-ការងារគ្រប់គ្រងមុខសញ្ញា និងបច្ចេកវិទ្យា**

-តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបម្រើឱ្យការងារគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅកម្ពុជា FPCS ដែលក្រសួងបានដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ គិតត្រឹមចុងខែកញ្ញា ឆ្នាំ២០២១ នេះ ពិនិត្យឃើញថា ជនបរទេសដែលបានរាយការណ៍អំពីវត្តមានស្នាក់នៅរបស់ខ្លួននៅក្នុងប្រព័ន្ធ មានចំនួន ៦៣៤.៩០៩នាក់/២០២សញ្ជាតិ ។ ដើម្បីផ្តល់ភាពងាយស្រួលដល់សមត្ថកិច្ចពាក់ព័ន្ធ(ជាពិសេសនគរបាលប៉ុស្តិ៍រដ្ឋបាល) ក្នុងការគ្រប់គ្រងជនបរទេសដែលកំពុងស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន ក្រសួងបានបង្កើតគណនីសមត្ថកិច្ចក្នុងប្រព័ន្ធ FPCS ចំនួន ៤.០១២គណនី ។

-ដោយឡែក ចំពោះការងារគ្រប់គ្រងបញ្ជីខ្មៅអន្តោប្រវេសន៍ ក្នុងរយៈពេល ០៩ខែ នេះ ៖

+បញ្ចូលមុខសញ្ញាថ្មីបន្ថែមចំនួន ៤.៥៨៣នាក់/៩៩សញ្ជាតិ សរុបមានចំនួន ២៣.៦៦១នាក់ ក្នុងនោះមុខសញ្ញា A, B, C, D, E ចំនួន ២.១៦៥នាក់ ។

+ធ្វើបច្ចុប្បន្នភាពទិន្នន័យការពារសុវត្ថិភាពអ្នកដំណើរ ៧៣៤នាក់/៤៩សញ្ជាតិ ។

**ឃ-ការងារស៊ើបអង្កេត និងអនុវត្តនីតិវិធី**

-បានរកឃើញ ឃាត់ខ្លួន និងបណ្តេញចេញជនបរទេសល្មើសច្បាប់ចេញពីប្រទេសតាមនីតិវិធីច្បាប់ចំនួន ២.២៦៦នាក់/៤២សញ្ជាតិ។ ទន្ទឹមនេះ ក៏មានជនបរទេសចំនួន ២៦៤នាក់/១៦សញ្ជាតិ កំពុងស្ថិតនៅក្នុងស្នាក់ការត្រៀមបណ្តេញចេញផងដែរ ។

-បង្ក្រាបជនបរទេសប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសបានចំនួន ៦០១លើក មនុស្ស ២.៦៣៧នាក់ មាន ២២សញ្ជាតិ ។ ដោយឡែក ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុ និងបទល្មើសផ្សេងៗមានចំនួន ២៨៤លើក មនុស្ស ៣២៧នាក់ ក្នុងនោះ ស្លាប់ដោយសារជំងឺ ២០៦នាក់ ឃាតកម្ម ០៩នាក់ អត្តឃាត ១៥នាក់ គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ផ្សេងៗ ៣២នាក់ និងរងគ្រោះដោយអំពើផ្សេងៗ ៦៥នាក់ ។

## ៦-ការងារពន្ធនាគារ

គិតត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ នេះ ជនជាប់ឃុំមានចំនួនសរុប ៣៧.៤៤១នាក់ ស្រី ២.៣៥១នាក់ ក្នុងនោះមាន ៖ ជនត្រូវចោទ ៥.៩០២នាក់ (ស្រី ៣៥៦នាក់ ជនបរទេស ៣៩៩នាក់ អនីតិជន ៣៨៧នាក់) ជនជាប់ចោទ ៤.៣៣០នាក់ (ស្រី ២៥១នាក់ ជនបរទេស ១៧៦នាក់ អនីតិជន ៣៤៧នាក់) ពិរុទ្ធជន ១៤.៦២៦នាក់ (ស្រី ៩២៣នាក់ ជនបរទេស ៧២៨នាក់ អនីតិជន ៣១០នាក់) ទណ្ឌិត ១២.៥៨៣នាក់ (ស្រី ៨២១នាក់ ជនបរទេស ៣៥១នាក់ អនីតិជន ២៨៩នាក់) ។ កត់សម្គាល់៖ ក្នុងរយៈពេល ០៩ខែ នេះ ស្ថានភាពចំនួនជនជាប់ឃុំមានការប្រែប្រួល ជាអាទិ៍ ៖ ចាប់ចូលថ្មី ១៣.៦០៥នាក់ ស្រី ៩១៥នាក់ អនុវត្តដីកាដោះលែង ១៥.២៥២នាក់ ស្រី ១.១៥១នាក់ ស្លាប់ ២២២នាក់ និងរត់រួច ០៧នាក់ ។

**-អំពីការងារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពពន្ធនាគារ៖** ក្រសួងមហាផ្ទៃបានបន្តខិតខំជំរុញការគាំទ្រទាំងផ្នែកស្មារតី និងធនធានសម្ភារៈបច្ចេកទេស ព្រមជាមួយនឹងការអនុវត្តច្បាប់មឺុងម៉ាត់ ដើម្បីស្តារស្ថានការណ៍នានាដែលពន្ធនាគារបាន និងកំពុងប្រឈម ។ ទន្ទឹមនឹងការយកចិត្តទុកដាក់អនុវត្តយន្តការដែលមានស្រាប់ វិធានការជាច្រើន ក៏ត្រូវបានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់ សម្រាប់ជួយគាំទ្រដល់ការងារពង្រឹងសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយនៅក្នុងពន្ធនាគារ ព្រមទាំងសុខភាពអនាម័យរបស់ជនជាប់ឃុំផងដែរ ហើយក្នុងនោះ កត់សម្គាល់ឃើញថា នៅគ្រប់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត បានអនុវត្តត្រឹមត្រូវតាមវិធានសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ប៉ុន្តែជាមួយគ្នានោះ ដោយភាពធកល្វែងខ្លះ បានបណ្តាលឱ្យជនជាប់ឃុំមានឱកាសធ្វើសកម្មភាពល្មើសបានដោយអន្លើរ ដែលក្នុងរយៈពេលនេះ មន្ត្រីអនុរក្សពន្ធនាគារបានឆែករកឃើញ និងដកហូតបាននូវទូរស័ព្ទដៃចំនួន ៣០គ្រឿង ព្រមទាំងសម្ភារៈហាមឃាត់មួយចំនួន និងក្រៅពីនេះ ក៏មានករណីជនជាប់ឃុំលួចរត់គេចខ្លួនរួចចំនួន ០៧នាក់ ផងដែរ ។

**-អំពីការងារអប់រំកែប្រែ និងស្តារនីតិសម្បទា ៖** បានអនុញ្ញាតឱ្យជនជាប់ឃុំចំនួន ១១៤.៧៦៥នាក់ ស្រី ៧.៩១៦នាក់ ចូលរៀនអំពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ អក្ខរកម្ម ថ្នាក់មូលដ្ឋាន ភាសាបរទេស សីលធម៌ បំណិនជីវិត ធ្វើលំហាត់ប្រាណ លេងកីឡា... ផ្តល់សេវាពិនិត្យ ព្យាបាលជំងឺដល់ជនជាប់ឃុំដែលមានបញ្ហាសុខភាពបានចំនួន ២៤៤.៩១៦នាក់ និងបានរៀបចំវាយតម្លៃលក្ខណសម្បត្តិទណ្ឌិតដែលស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងឱកាសពិធីបុណ្យជាតិផ្សេងៗសម្រាប់ឆ្នាំ២០២១ ចំនួន ១.៩៧០នាក់ ស្រី ១៩៣នាក់ *(អនុវត្តតាមព្រះរាជក្រឹត្យត្រាស់បង្គាប់បន្ធូរបន្ថយទោស និងលើកលែងទោសដល់ទណ្ឌិតចំនួន ៣៦០នាក់ ស្រី ៤៤នាក់)* ។

**-អំពីការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ៖** ក្រសួងបានបន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីៗ លើជំនាញវិជ្ជាជីវៈដូចជា រៀនកាត់ដេរ កាត់សក់ សំអាងការ គូរគំនូរ របាំ កុំព្យូទ័រ ជួសជុលយានយន្ត ម៉ូតូ បរិក្ខារត្រជាក់ និងអេឡិចត្រូនិច រៀនបច្ចេកទេសកសិកម្ម សិប្បកម្ម សំណង់ស៊ីវិល និងជំនាញផលិតកម្ម... ដែលក្នុងនោះ មានជនជាប់ឃុំចូលរួមប្រមាណជាង ១.៨៨៧នាក់ ស្រី ១៥៧នាក់ ។

**-លើការងារអភិវឌ្ឍពន្ធនាគារ ៖** ក្រសួងបាន និងកំពុងដំណើរការសាងសង់ ជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបំពាក់សម្ភារៈបច្ចេកទេសនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនានា ក្រោមគម្រោងប្រើប្រាស់ថវិការដ្ឋចំនួន ០៣គម្រោង និងថវិការបស់ដៃគូអភិវឌ្ឍ ០៨គម្រោង ។

## ៧-ការងារបណ្ឌិត្យសភានគរបាលកម្ពុជា

-បានដំណើរការវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារសរុបចំនួន ២៣ថ្នាក់-វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សនគរបាលជាតិសរុបចំនួន ១.៤០៩រូប ស្រី ២៥៤រូប ដែលក្នុងនោះ វគ្គសិក្សាបាន

បញ្ចប់ជាស្ថាពរចំនួន ០១វគ្គសិក្សា មាននិស្សិត និងសិស្សនគរបាលជាតិចំនួន ២៣៤រូប ស្រី ៥១រូប ថ្នាក់កំពុងសិក្សាចំនួន ១៦ថ្នាក់ មាននិស្សិត និងសិស្សនគរបាលជាតិសរុបចំនួន ៨៨៦រូប ស្រី ១៧៨រូប និងថ្នាក់ត្រៀមប្រឡងបញ្ចប់ការសិក្សាចំនួន ០២ថ្នាក់ មាននិស្សិត និងសិស្សនគរបាលជាតិសរុបចំនួន ៧២រូប ស្រី ១៣រូប។ ចំពោះវគ្គបណ្តុះបណ្តាល និងវគ្គសិក្សាដែលនៅសល់ ត្រូវបានសម្រេចផ្អាកជាបណ្តោះអាសន្ន ដោយសារការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ។

-បានរៀបចំចាត់បញ្ជូនគ្រូនគរបាលជាតិចូលរួមវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងសិក្ខាសាលាតាមប្រព័ន្ធអនឡាញនៅក្នុង និងក្រៅប្រទេសចំនួន ១១៨រូប ។

-បានរៀបចំផ្លាស់ប្តូរកម្រិតគ្រូនគរបាលជាតិចំនួន ១០២រូប ។

-បានបន្តជំរុញដំណើរការសិក្សាកែសម្រួល និងអភិវឌ្ឍកម្មវិធីអប់រំគ្រប់កម្រិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពប្រើប្រាស់កម្លាំង ។ ក្នុងនោះ ដំណើរការរៀបចំមុខវិជ្ជាសៀវភៅគោលចំនួន ១៧០មុខវិជ្ជា មកទល់ពេលនេះ សម្រេចបាន ៩៨,២៣% ។

-បាន និងកំពុងជំរុញការសិក្សាកែសម្រួល និងអភិវឌ្ឍកម្មវិធីអប់រំគ្រប់កម្រិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពប្រើប្រាស់កម្លាំង ។

-បាន និងកំពុងរៀបចំគម្រោងស្រាវជ្រាវលើប្រធានបទមួយចំនួនដូចជា ៖ ១.បញ្ហាប្រឈមនៃការរីករាលដាលប្រើប្រាស់គ្រឿងញៀនក្នុងស្រទាប់យុវវ័យ ២.ស្ថានភាពបច្ចុប្បន្ន និងការប្រឈមចំពោះមុខនៃអំពើជួញដូរមនុស្សតាមប្រព័ន្ធអនឡាញនៅកម្ពុជា ៣.ភាពមិនរាងចាលនៃទណ្ឌិត និង ៤.យុទ្ធសាស្ត្រ និងយន្តការក្នុងការងារបង្ការទប់ស្កាត់បទល្មើសលួច។ ជាមួយគ្នានេះ ក៏កំពុងត្រៀមអនុវត្តគម្រោងស្តីពី ការស្ទង់មតិលើលទ្ធផលបំពេញការងាររបស់អតីតនិស្សិតជ័យលាភីនៅបណ្ឌិត្យសភាននគរបាលកម្ពុជា ផងដែរ ។

-បានបន្តយកចិត្តទុកដាក់ជំរុញកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នជាតិ អន្តរជាតិ និងគ្រឹះស្ថានឧត្តមសិក្សានានា ដែលជាដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធន៍លើការងារបណ្តុះបណ្តាលដល់កងកម្លាំងនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ។ ជាក់ស្តែងនៅក្នុងរយៈពេល ០៩ខែ ឆ្នាំ២០២១ នេះ ៖

+បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងបណ្ឌិត្យសភាននគរបាលកម្ពុជា (PAC) និងសាកលវិទ្យាល័យរ៉ាស្ត្រីយ៉ារ័កហ្សា (RRU) ប្រទេសឥណ្ឌា តាមប្រព័ន្ធអនឡាញ ។

+បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការផ្នែកសិក្សាធិការរវាងបណ្ឌិត្យសភាននគរបាលកម្ពុជា (PAC) និងមហាវិទ្យាល័យនគរបាលខេត្តយូណាន (YNPC) ប្រទេសចិន តាមប្រព័ន្ធអនឡាញ ។

## ៨-ការងារតស្លការ និងហិរញ្ញវត្ថុ

### ក-ការងារគ្រប់គ្រងហិរញ្ញវត្ថុ

#### ក.១-ការងារហិរញ្ញវត្ថុផ្នែកសន្តិសុខសាធារណៈ

-ឥណទានដែលបានអនុម័តសរុបមានចំនួន ១.៧០៤.៨៥៦.៥០០.០០០រៀល ឥណទានដែលបានអនុវត្តក្នុងរយៈពេល ០៩ខែ នេះ មាន ១.២០២.៦០៨.៦៣៣.៣៣២រៀល ស្មើ ៧០,៥០% ។

-គិតត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១ បង់ចំណូលចូលថវិកាជាតិបាន ៩៥.៨៧៥.២៣១.៧៤០រៀល ស្មើ ២២,០៥% នៃផែនការឆ្នាំ ។

-បញ្ជូនសលាកបត្រស្នើសុំធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៥៣៨សលាកបត្រ និងអាណត្តិបើកប្រាក់ចំនួន ៤០៧ច្បាប់ ។

-រៀបចំកត់ត្រារថយន្ត និងមធ្យោបាយដឹកជញ្ជូនផ្សេងៗចំនួន ១៤៧គ្រឿង បញ្ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

-រៀបចំទីតាំងដីទំហំ ២.៥២០ម² ជូនមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ និងកំពុងបំពេញទិន្នន័យទីតាំងដីចំនួន ១៦ក្បាលដី ជូនអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង ៣៥ក្បាលដី ជូនស្នងការដ្ឋាននគរបាលខេត្តកោះកុង។

-បាន និងកំពុងរៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០២២-២០២៤) ព្រមទាំងគម្រោងចំណូល-ចំណាយថវិការបស់ក្រសួងមហាផ្ទៃ សម្រាប់ប្រើប្រាស់ឆ្នាំ២០២២ ផ្នែកសន្តិសុខសាធារណៈ ។

-គិតមកដល់បច្ចុប្បន្ន មន្ត្រីនគរបាលជាតិដែលបើកបៀវត្សតាមប្រព័ន្ធធនាគារ សរុបមាន ៩៦,៣៩% ។

**ក.២-ការងារហិរញ្ញវត្ថុផ្នែករដ្ឋបាលទូទៅ**

-ឥណទានដែលបានអនុម័តសរុបមានចំនួន ៣០៣.៦៥៥.៧០០.០០០រៀល ឥណទានដែលបានអនុវត្តក្នុងរយៈពេល ០៩ខែ នេះ មាន ២១៧.៨១៧.២៥១.៥៥៦រៀល ស្មើ ៧១,៧៣% ។

-បញ្ជូនសលាកបត្រស្នើសុំធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៣៩៩សលាកបត្រ និងអាណត្តិបើកប្រាក់ចំនួន ១៩៤ច្បាប់ ។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័តលើការធានាចំណាយ ១៩គម្រោង ក្នុងនោះ បានបើកកញ្ចប់ដេញថ្លៃរួច ១០គម្រោង និងពិគ្រោះ-ចរចាថ្លៃ ០២គម្រោង ។

-ប្រគល់ទទួលចំនួន ០៣គម្រោង រួមមាន ៖ ឯកសណ្ឋានមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ និងមន្ត្រីពន្ធនាគារ ការផ្គត់ផ្គង់សម្ភារៈជូនជនជាប់ឃុំ និងការផ្គត់ផ្គង់ប្រេងឥន្ធនៈឆ្នាំ២០២១ ។

-រៀបចំផែនការសកម្មភាពលម្អិត (Map3+2) សម្រាប់អនុវត្តឆ្នាំ២០២១ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-បាន និងកំពុងរៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០២២-២០២៤) ព្រមទាំងគម្រោងចំណូល-ចំណាយថវិការបស់ក្រសួងមហាផ្ទៃ សម្រាប់ប្រើប្រាស់ឆ្នាំ២០២២ ផ្នែករដ្ឋបាលទូទៅ ។

-ដោយឡែក ចំពោះការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត(គិតពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១)៖ ចំណូលសរុប ៥.៦៧៧.០០០.០០០រៀល អនុវត្តបាន ២.២៥២.៥០០.០០០រៀល ។

**ខ-ការងារគស្តុគារ និងស្រាវជ្រាវឧបករណ៍ សម្ភារៈបច្ចេកទេស**

-បានផ្គត់ផ្គង់ប្រេងឥន្ធនៈ និងស្បៀង សម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការរបស់កងកម្លាំងនគរបាលជាតិ រួមមាន៖ ប្រេងសាំង ៦.៦៥៥.០៩៥លីត្រ ប្រេងសាំងស៊ុបពែរ ១៧៣.៧៣៧លីត្រ ប្រេងម៉ាស៊ូត ៣.៤២៤.៣០៩ លីត្រ ប្រេងម៉ាស៊ីនស៊ុបពែរ ២០.៤៣០លីត្រ ប្រេងម៉ាស៊ីន ១៦.០១៦លីត្រ អង្ករគោលដៅ ៧១២.៨៨៩គ.ក្រ មីកញ្ចប់ ២១.៥៣៨កេសតូច ត្រីខកំប៉ុង ២.៩២២កេស និងទឹកបរិសុទ្ធ ១១.៩៥០កេស ។

-បញ្ចប់ការបើកផ្តល់ជូននាយកដ្ឋាន-អង្គភាពចំណុះក្រសួង និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រួមមាន ៖ ឯកសណ្ឋានគោលរបបឆ្នាំ២០២០ សម្ភារៈការិយាល័យ គ្រឿងសង្ហារិមគោលរបបឆ្នាំ២០២០ និងសម្ភារៈបរិក្ខារមិនមែនព័ត៌មានវិទ្យាគោលរបបឆ្នាំ២០២០ ។

-ទទួលទំហំខ្នាតឯកសណ្ឋាន និងលក្ខណៈសញ្ញាស័ក្តិកងកម្លាំងនគរបាលជាតិគោលរបបឆ្នាំ២០២១ ពីនាយកដ្ឋាន-អង្គភាព ចំនួន ៥១ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន ២៥ ។

-ផ្គត់ផ្គង់ជូនបណ្តានាយកដ្ឋាន-អង្គភាពចំណុះក្រសួង និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រួមមានៈ ប្រេងម៉ាស៊ីនគោលរបបឆ្នាំ២០២១ ប្រេងបេសកកម្មត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ គោលរបបឆ្នាំ២០២១ និងអង្ករគោលដៅត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ គោលរបបឆ្នាំ២០២១ ។

-បញ្ចប់ការបើកផ្តល់ទឹកបរិសុទ្ធគោលរបបត្រីមាសទី១ ត្រីមាសទី២ ឆ្នាំ២០២១ ជូននាយកដ្ឋាន-អង្គភាពចំណុះក្រសួងមហាផ្ទៃ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រួចរាល់ រីឯគោលរបបត្រីមាសទី៣ បានចំនួន ៣៤ អង្គភាព។

**គ-ការងារសុខាភិបាល ស្ថាបនា ផ្សព្វផ្សាយអប់រំ**

**គ.១-ការងារសុខាភិបាល**

-បានពិនិត្យ ព្យាបាលជំងឺជូនកងកម្លាំងនគរបាលជាតិនៅតំបន់ប្រាសាទព្រះវិហារចំនួន ២.៦១១រូប និងនៅមន្ទីរពេទ្យ ១៦ឧសភា ចំនួន ១.៨៥៤រូប ។

-បានចាត់ក្រុមគ្រូពេទ្យចុះទៅពិនិត្យសុខភាពដល់កងកម្លាំងនគរបាលជាតិនៅភូមិភាគ៥ ចំនួន ៤៦១រូប និងជនអន្តោប្រវេសន្ត (មុននឹងរៀបចំនីតិវិធីបណ្តេញចេញពីកម្ពុជា) ចំនួន ១.១៦២នាក់ ។

-បានបើកផ្តល់ឱសថ និងបរិក្ខារវេជ្ជសាស្ត្រ ជូនដល់កងកម្លាំងនគរបាលជាតិសម្រាប់ព្យាបាលជំងឺចំនួន ១៥១ប័ណ្ណ និង១២០វិក្កយបត្រ ។

-បានបន្តយកចិត្តទុកដាក់ជំរុញការអនុវត្តវិធានការបង្ការ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅគ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ។ ទន្ទឹមនេះ ក៏បានចូលរួមសហការជាមួយក្រសួងសុខាភិបាលចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ថ្នាក់នៃក្រសួងមហាផ្ទៃ ជនជាប់ឃុំនៅក្នុងពន្ធនាគារ ព្រមទាំងប្រជាពលរដ្ឋ ដើម្បីទប់ស្កាត់ និងកាត់ផ្តាច់ការឆ្លងរាលដាលចូលក្នុងសហគមន៍ផងដែរ ។

-បានរៀបចំសិក្ខាសាលាស្តីពី សុខភាពនគរបាលចំនួន ០១លើក និងចុះអប់រំសុខភាពស្តីពី ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៅស្នងការដ្ឋាននគរបាលខេត្តចំនួន ០២ខេត្ត ។

**គ.២-ការងារស្ថាបនា**

-បាន និងកំពុងដំណើរការសាងសង់ ជួសជុលអគារធ្វើការ អគារសិក្សា អគារស្នាក់នៅរបស់កងកម្លាំងនគរបាលជាតិសរុបចំនួន ០៩គម្រោង និងការសាងសង់ផ្លូវថ្នល់ ស្ពាន លូ ចំនួន ២៥គម្រោង ស្ថិតក្នុងខេត្តព្រៃវែង កណ្តាល សៀមរាប បាត់ដំបង កំពង់ស្ពឺ តាកែវ និងខេត្តពោធិ៍សាត់ ។

-បើកកញ្ចប់ឯកសារដេញថ្លៃចំនួន ១៩គម្រោង បញ្ចប់ការសិក្សាប្លង់គម្រោងចំនួន ១០គម្រោង និងកំពុងសិក្សាប្លង់គម្រោងចំនួន ០៨គម្រោង ។

**គ.៣-ការងារផ្សព្វផ្សាយអប់រំ**

-បានធ្វើការផ្សព្វផ្សាយព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួងមហាផ្ទៃ តាមបណ្តាញទំនាក់ទំនងសង្គមចំនួន ១១.២០៥អត្ថបទ ។

-បានបោះពុម្ព និងចែកផ្សាយទស្សនាវដ្តីមិត្តនគរបាលចំនួន ០៥លេខ(ពីលេខ ៩៦ ដល់លេខ ១០០) ជូននាយកដ្ឋាន-អង្គភាពចំណុះក្រសួង ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ។

**ឃ-ការងារអធិការកិច្ច**

ក្នុងរយៈពេល ០៩ខែ ឆ្នាំ២០២១ នេះ ក្រសួងមហាផ្ទៃទទួលបានរបាយការណ៍បំភ្លឺពីអង្គភាពថ្នាក់កណ្តាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចំនួន ១៥៣របាយការណ៍ និងទទួលពាក្យបណ្តឹង

ចំនួន ៧៩៥សំណុំរឿង ដែលគិតទាំងបណ្ដឹងនៅសល់ពីឆ្នាំ២០២០ ចំនួន ៣០៥សំណុំរឿង សរុបបណ្ដឹងមានចំនួន ១.១០០សំណុំរឿង ក្នុងនោះ ៖

-ផ្នែករដ្ឋបាល ៖ របាយការណ៍បំភ្លឺចំនួន ៩០របាយការណ៍ និងបណ្ដឹងចូលថ្មីចំនួន ៥៤៤សំណុំរឿង គិតទាំងបណ្ដឹងនៅសល់ពីឆ្នាំ២០២០ ចំនួន ១៦១សំណុំរឿង សរុបបណ្ដឹងចំនួន ៧០៥សំណុំរឿង ។

-ផ្នែកនគរបាល៖ របាយការណ៍បំភ្លឺចំនួន ៦៣របាយការណ៍ និងបណ្ដឹងចូលថ្មីចំនួន ២៥១សំណុំរឿង គិតទាំងបណ្ដឹងនៅសល់ពីឆ្នាំ២០២០ ចំនួន ១៤៤សំណុំរឿង សរុបបណ្ដឹងចំនួន ៣៩៥សំណុំរឿង ។

ជាលទ្ធផល ក្រសួងបានដោះស្រាយបញ្ចប់ និងបង្វែរបណ្ដឹងជូនទៅស្ថាប័នពាក់ព័ន្ធ និងសាមីបណ្ដឹងវិញសរុបចំនួន ៤៩១សំណុំរឿង (ដោះស្រាយបញ្ចប់ ៣៨សំណុំរឿង បង្វែរទៅស្ថាប័នពាក់ព័ន្ធ ៣០១សំណុំរឿង និងរក្សាទុកតាមដានបន្ត ១៥២សំណុំរឿង)។ រីឯបណ្ដឹងដែលនៅសេសសល់ ក្រសួងកំពុងជំរុញការចុះអង្កេតស្រាវជ្រាវ និងដោះស្រាយតាមនីតិវិធី ។

ដោយឡែក លើការងារពង្រឹងគណនេយ្យភាពរបស់អង្គភាពក្រោមឱវាទ ក្រសួងបានចាត់មន្ត្រីចុះតាមដានការអនុវត្តសេចក្ដីជូនដំណឹងដែលបានដាក់ចេញនាពេលកន្លងមក រួមមាន ៖ ផ្នែករដ្ឋបាលចំនួន ១៤សជណ និងផ្នែកនគរបាលចំនួន ១៣សជណ ។

<u>កត់សម្គាល់៖</u> អនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាដើម្បីចូលរួមបង្ការ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងបានផ្អាកដំណើរការចុះធ្វើសកម្មភាពអធិការកិច្ចមួយអន្លើ (ចាប់ពីខែមេសាដល់ខែឧសភា)។ ដោយឡែក សកម្មភាពការងារទទួល និងតាមដានអំពីការដោះស្រាយការបញ្ចេញមតិ យោបល់ ឬសំណូមពររបស់មហាជន នៅក្នុងទំព័រហ្វេសប៊ុក **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បាន និងកំពុងដំណើរការយ៉ាងសស្រាក់សស្រាំ និងកាន់តែទទួលបានការគាំទ្រកាន់តែខ្លាំងឡើង ។

## ១០-ការងារសវនកម្មផ្ទៃក្នុង

នៅក្នុងឆ្នាំ២០២១ នេះ ក្រសួងមហាផ្ទៃបានកំណត់ផែនការចុះធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទ ២០១៩ ការិយបរិច្ឆេទ ២០២០ និងឆ្នាំពាក់ព័ន្ធ សរុបចំនួន ១.៥៥៩គោលដៅ និងគោលដៅចាំបាច់មួយចំនួនទៀត ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ដូចជាអនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមបង្ការ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ ក្រសួងពុំបានដំណើរការអនុវត្តផែនការខាងលើនេះ នៅឡើយទេ ។ ទោះបីយ៉ាងនេះក្ដី ក្រសួងនៅតែបន្តយកចិត្តទុកដាក់ខ្ពស់ទៅលើការបញ្ជ្រាបគោលគំនិតសុចរិតភាព និងអភិបាលកិច្ចដល់អង្គភាពចំណុះគ្រប់ថ្នាក់ ដើម្បីពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ។ ជាមួយគ្នានេះ ក្រសួងក៏បាន និងកំពុងបំពាក់បំប៉នជំនាញដល់មន្ត្រីសវនករជាប្រចាំ ដើម្បីត្រៀមលក្ខណៈចុះធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាពនាពេលខាងមុខផងដែរ ។

## ១១-ការងារទំនាក់ទំនងអន្តរជាតិ

បើទោះបីស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ តម្រូវឱ្យមានការកាត់បន្ថយកិច្ចជំនួបដោយផ្ទាល់ក៏ពិតមែន ប៉ុន្តែក្រសួងមហាផ្ទៃនៅតែបន្តខិតខំពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អទាំងក្នុងកម្រិតតំបន់ និងអន្តរជាតិ តាមរយៈការប្រើប្រាស់យន្តការផ្សារភ្ជាប់ទំនាក់ទំនងតាមគ្រប់លទ្ធភាព ដើម្បីធានារក្សាឱ្យបាននូវគ្រប់សម្ព័ន្ធភាពដែលមាន ជាមួយនឹងការខិតខំបង្កើតចំណងមិត្តភាពថ្មីៗបន្ថែមទៀត សំដៅកៀរគរការចូលរួមគាំទ្រកាន់តែសកម្មផុលផុសពីគ្រប់មជ្ឈដ្ឋាន នៅក្នុងដំណើរការនៃការអនុវត្តកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល និងផែនការអភិវឌ្ឍនានាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ក៏ដូចជាការអនុវត្តកិច្ចការអាទិភាព

ផ្សេងទៀតដែលបម្រើដល់ឧត្តមប្រយោជន៍ជាតិ និងប្រជាជន។ ជាក់ស្តែង ទន្ទឹមនឹងការជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ តាមយន្តការនានាក្នុងរបត់នៃគន្លងថ្មី ក្រសួងមហាផ្ទៃក៏បានអនុញ្ញាតឱ្យអង្គទូត និងឥស្សរជននៃបណ្តាប្រទេស និងអង្គការអន្តរជាតិនានាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារផ្លូវការចំនួន ១២លើក ផងដែរ ។

<u>កត់សម្គាល់</u> ៖ ក្នុងក្របខ័ណ្ឌ SOMTC ក្រុមការងារបានបង្កើតក្រុមលេខាទទួលភារកិច្ចតាមផែននីមួយៗ ដែលមានសមាសភាពសរុបចំនួន ៤៧រូប ផ្តល់យោបល់ និងធាតុចូលលើសំណើ និងឯកសារពាក់ព័ន្ធចំនួន ៤៩ករណី-ឯកសារ និងចូលរួមសិក្ខាសាលា វេទិកា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំនានាចំនួន ១៧លើក។ តាមរយៈប្រព័ន្ធ **I-24/7** ក្រសួងមហាផ្ទៃបានស្នើសុំព័ត៌មានចំនួន ១៥ករណី (ទទួលបានការឆ្លើយតប ០៣ករណី) ទទួលសំណើចំនួន ២២១ករណី និងឆ្លើយតបទៅសាមីប្រទេសវិញបានចំនួន ៨៣ករណី ។ សហការបង្ក្រាបបទល្មើសឧក្រិដ្ឋកម្មឆ្លងដែន ០៤ករណី ឃាត់មុខសញ្ញា ២២នាក់ ។

## ១២-ការងារអភិវឌ្ឍធនធានមនុស្ស

### ក-ផ្នែកមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ

-គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ មានចំនួនសរុប ៧.០៤៨រូប ស្រី ១.២៥០រូប រួមមាន មន្ត្រីរដ្ឋបាលស៊ីវិល(ថ្នាក់ជាតិ ៩៧៩រូប ស្រី ២៤៧រូប ថ្នាក់ក្រោមជាតិ ៣.០៤០រូប ស្រី ៥៥៥រូប) និងមន្ត្រីពន្ធនាគារ (ថ្នាក់ជាតិ ១.១៥៨រូប ស្រី ១៨៣រូប ថ្នាក់ក្រោមជាតិ ១.៨៧១រូប ស្រី ២៦៥រូប) ។ <u>កត់សម្គាល់</u> ៖ បានផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌចំនួន ៩៥រូប ស្រី ១២រូប កាត់ចេញពីក្របខ័ណ្ឌ ២៨៩រូប ស្រី ៦៤រូប (ផ្ទេរក្របខ័ណ្ឌចេញ ៣៣រូប ស្រី ០៨រូប លុបឈ្មោះដោយមរណភាព ១២រូប ស្រី ០១រូប លុបឈ្មោះចេញពីក្របខ័ណ្ឌ ០៥រូប ស្រី ០២រូប លុបឈ្មោះដោយកំហុសខាងវិន័យ ០៧រូប ស្រី ០២រូប និងដាក់ឱ្យចូលនិវត្តន៍ ២៣២រូប ស្រី ៥១រូប) អនុញ្ញាតឱ្យឈប់សម្រាកលំហែមាតុភាព ៤៨រូប ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ០៥រូប ស្រី ០១រូប និងអនុញ្ញាតឱ្យចូលបម្រើការងារក្នុងអង្គភាពដើមវិញ ០៤រូប ស្រី ០២រូប។ តែងតាំងប្រគល់ភារកិច្ច និងផ្ទេរភារកិច្ចជូនមន្ត្រីរដ្ឋបាលស៊ីវិលនៅថ្នាក់ជាតិចំនួន ១៤៨រូប ស្រី ២៤រូប និងថ្នាក់ក្រោមជាតិ ២៣៦រូប ស្រី ៥៥រូប ។ រៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការចំនួន ១១វគ្គ សិក្ខាកាម ៣៩៩រូប ស្រី ៨៣រូប និងចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានៅក្នុងប្រទេសចំនួន ០៨វគ្គ សិក្ខាកាម ៤៣៧រូប ស្រី ៦៩រូប និងក្រៅប្រទេសចំនួន ០២រូប ស្រី ០១រូប (សម្រាប់រយៈពេលវែង) ។

-បច្ចុប្បន្ន សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សរុបមានចំនួន ១៥.៦៩៩រូប ស្រី ៣.១៥០រូប។ <u>កត់សម្គាល់</u>៖ បានសម្រេចផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចំនួន ២១៩រូប ស្រី ១៩រូប ក្នុងនោះ នៅថ្នាក់រាជធានី ខេត្ត ១៣រូប (ជំនួសសមាសភាពដែលមរណភាព ០៧រូប និងលាលែងពីការងារ ០៦រូប) នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ៥២រូប ស្រី ០៥រូប (ជំនួសសមាសភាពដែលមរណភាព ២៩រូប បាត់បង់សមាជិកភាព ០៥រូប និងលាលែងពីការងារ ១៨រូប) និងនៅថ្នាក់ឃុំ សង្កាត់ ១៥៤រូប ស្រី ១៤រូប (ជំនួសសមាសភាពដែលមរណភាព ១៣៣រូប បាត់បង់សមាជិកភាព ០៥រូប និងលាលែងពីការងារ ១៦រូប) ។

### ខ-ផ្នែកកងកម្លាំងនគរបាលជាតិ (ឆព្វមាស គិតពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១)

គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិនៅទូទាំងប្រទេសមានចំនួន ៦១.២១៨រូប ស្រី ៥.៦១៦រូប (ថ្នាក់ជាតិ ២១.៥២៧រូប ស្រី ២.០០០រូប និងថ្នាក់ក្រោមជាតិ ៣៩.៦៩១រូប ស្រី ៣.៦១៦រូប) ។

កត់សម្គាល់៖ បានផ្ទេរចូលក្របខ័ណ្ឌចំនួន ៨៩រូប ស្រី ១០រូប បញ្ចូលក្របខ័ណ្ឌថ្មី ២.៤៩៤រូប ស្រី ៣៣៦រូប ដាក់ឱ្យចូលនិវត្តន៍ ២២៦រូប (ថ្នាក់ជាតិ ១១៦នាក់ និងថ្នាក់ក្រោមជាតិ ១១០នាក់) និងដាក់វិន័យចំនួន ១៦៨រូប ស្រី ០៥នាក់ (បណ្តេញចេញពីក្របខ័ណ្ឌ ៤០រូប) ។ ផ្ទេរភារកិច្ច សម្រួលភារកិច្ច និងតែងតាំងមុខតំណែងសរុប ចំនួន ៤.០៩១រូប ស្រី ៣៨៩រូប (ថ្នាក់ជាតិ ១.៣៨១រូប ស្រី ១៣៣រូប និងថ្នាក់ក្រោមជាតិ ២.៧១០រូប ស្រី ២៥៦ នាក់) និងដំឡើងឋានន្តរស័ក្តិសរុបចំនួន ៨.៤៨១រូប ស្រី ៦៦៧រូប (ថ្នាក់ជាតិ ១.៩៥២រូប ស្រី ១៧៨រូប និងថ្នាក់ក្រោមជាតិ ៦.៥២៩រូប ស្រី ៤៨៩រូប) ។

## II-ទិសដៅការងារសម្រាប់អនុវត្តបន្ត

នៅក្នុងឆ្នាំ២០២២ ខាងមុខនេះ ក្រសួងនឹងបន្តខិតខំជំរុញដល់បណ្តាអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ឱ្យបន្តអនុវត្តបញ្ចប់ការងារសេសសល់ រួមទាំងការងារថ្មីៗដែលចាំបាច់ត្រូវអនុវត្ត ដូចបានកំណត់នៅក្នុងទិសដៅការងារទៅតាមជំនាញ ជាអាទិ៍ ៖

### ១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បន្តសហការរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្តដែលបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។

-បន្តសិក្សា ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ដែលនៅសេសសល់ និងសិក្សាស្រាវជ្រាវ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែម សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ។

### ២-ការងារគ្រប់គ្រងរដ្ឋបាលដែនដី

#### ក-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

**ក.១-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖** បន្តពិនិត្យ សិក្សា និងលើកយោបល់គោរពជូនរាជរដ្ឋាភិបាល ពិនិត្យ សម្រេចលើសំណើពាក់ព័ន្ធនឹងការស្នើសុំបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាល ។

**ក.២-ការងារសហការ សម្របសម្រួល ផ្តល់កិច្ចអន្តរាគមន៍ និងគាំទ្របច្ចេកទេស**

-បន្តសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា ក្នុងការអនុវត្តតួនាទី ភារកិច្ច ផែនការការងារ និងការអភិវឌ្ឍលើគ្រប់វិស័យនៅមូលដ្ឋាន និងការដោះស្រាយការលំបាក និងបញ្ហាប្រឈមនានាជូនប្រជាពលរដ្ឋ ។

-បន្តសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា ដើម្បីចូលរួមធ្វើឱ្យសម្រេចនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ។

**ក.៣-ការផ្តល់សេវា និងការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចុះតាមដានការអនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការផ្តល់សេវារដ្ឋបាលរបស់អង្គភាព-ការិយាល័យច្រកចេញចូលតែមួយ ។

-បន្តតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់ការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

-បន្តសិក្សា និងរៀបចំបែបបទ នីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ។

-បន្តគាំទ្របច្ចេកទេសលើការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាព និងការិយាល័យច្រកចេញចូលតែមួយ និងបន្តរៀបចំបង្កើតប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញ នៅការិយាល័យច្រកចេញចូលតែមួយដែលមិនទាន់មានប្រព័ន្ធនេះ ។

-បន្តសហការផ្សព្វផ្សាយ ផ្តល់វគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីដែលត្រូវជ្រើសរើសថ្មី និងមន្ត្រីដែលកំពុងបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ អំពីគោលការណ៍ និងលិខិតបទដ្ឋានថ្មីៗ ទាក់ទិននឹងការអនុវត្តការងាររបស់ការិយាល័យទាំងនេះ ។

**ក.៤-ការងារផ្ទេរមុខងារ និងធនធាន** ៖ បន្តសហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការគាំទ្រ និងតាមដាន ត្រួតពិនិត្យលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការរៀបចំឯកសារបច្ចេកទេស ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ ។

**ក.៥-ការគាំទ្រ និងតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តគាំទ្រ និងសម្របសម្រួលដល់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ។

-បន្តសម្របសម្រួល និងពិនិត្យការអនុវត្តតាមលក្ខខណ្ឌនានា ដើម្បីក្រុង ស្រុក និងឃុំ សង្កាត់ អាចទទួលបានថវិកាវិភាជន៍ទាន់ពេលវេលា ពិសេសពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍដែលប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ព្រមទាំងកសាងសមត្ថភាព និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឱ្យមានលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍនានា ។

-បន្តពិនិត្យ សិក្សា និងកែសម្រួលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

-បន្តពង្រឹងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រួមទាំងការគ្រប់គ្រងបញ្ជីសារពើភណ្ឌ ឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់នៃច្បាប់ ។

-បន្តសម្របសម្រួល និងកៀរគរដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ។

-បន្តតាមដានដំណើរការនៃការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងបន្តសិក្សាស្រាវជ្រាវអំពីបញ្ហារាំងស្ទះក្នុងការអនុវត្តគម្រោងក្រុង ស្រុក ។

**ក.៦-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងគម្រោងនានា**

-បន្តសហការជាមួយដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគម្រោងដែលកំពុងដំណើរការ ក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ។

-បន្តសម្របសម្រួលជាមួយដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំបង្កើតគម្រោងថ្មីផ្សេងទៀត សម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**ខ-ការងារតាមជំនាញដទៃទៀត**

**ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

-បន្តពិនិត្យ សិក្សា និងកែលម្អប្រព័ន្ធនីតិវិធី និងយន្តការគ្រប់គ្រងច្រកទ្វារព្រំដែន ។

-បន្តពិនិត្យលទ្ធភាពក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនថ្មី ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋ និងជំរុញការអភិវឌ្ឍតំបន់ព្រំដែន ។

-បន្តជំរុញការងារផ្តល់ប័ណ្ណព្រំដែន ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋចេញចូលឆ្លងកាត់ព្រំដែន។

-បន្តពិនិត្យ សិក្សា និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែន និងពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក និងច្រកទ្វារព្រំដែន ។

**ការងារវិនិយោគ អភិវឌ្ឍ និងអន្តរវិស័យ**

-បន្តអនុវត្តនីតិវិធីផ្តល់អនុលោមភាពលើគម្រោងរបស់រដ្ឋបាលរាជធានី ខេត្ត ។

-បន្តចុះពិនិត្យ វាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍរាជធានី ខេត្ត ដែលក្រសួងបានផ្តល់អនុលោមភាពរួច។

-បន្តពិនិត្យ សិក្សា សម្របសម្រួលលើករណីរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានាស្នើសុំវិនិយោគ អភិវឌ្ឍ និងកិច្ចការអន្តរវិស័យនានា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**រាជធានី ខេត្ត សម្ព័ន្ធមេត្រីភាព**

បន្តពិនិត្យ សម្រេចលើសំណើរបស់រដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការជាមួយខេត្តក្រុងនៃប្រទេសជាមិត្ត។ ទន្ទឹមនោះ បន្តពិនិត្យ វាយតម្លៃអំពីសកម្មភាព និងអត្ថប្រយោជន៍នានាដែលរាជធានី ខេត្តក្រុង ទទួលបានពីការចងសម្ព័ន្ធមេត្រីភាព ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរបទពិសោធន៍ល្អៗ សំដៅទាញយកផលប្រយោជន៍សម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ ទេសចរណ៍ នៅមូលដ្ឋាន ។

**ការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ**

-បន្តអនុវត្តនីតិវិធីលើសំណើសុំចុះបញ្ជីសហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដែលពាក់ព័ន្ធនឹងការងារសហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

-បន្តតាមដានជាប្រចាំនូវសកម្មភាពរបស់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

-បន្តសម្របសម្រួល ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារប្រចាំឆ្នាំ ស្របតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

-បន្តអនុវត្តនីតិវិធីលើសំណើសុំចុះបញ្ជី សុំបង្កើត និងសំណើផ្សេងៗដែលពាក់ព័ន្ធនឹងការងារគណបក្សនយោបាយ ។

-បន្តសម្របសម្រួល ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់គណបក្សនយោបាយក្នុងការធ្វើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពី គណបក្សនយោបាយ ។

**៣-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

-ប្តេជ្ញាការពារដាច់ខាតនូវបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ខឿនសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី រដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាលស្របច្បាប់ ព្រមទាំងធានាសុវត្ថិភាពនូវគ្រប់គោលដៅនយោបាយការទូត សេដ្ឋកិច្ច វប្បធម៌...។

-បន្តជំរុញលើកកម្ពស់ការអនុវត្តគោលនយោបាយ **"ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព"** គោលការណ៍ វិធានការ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ឱ្យបានសកម្មផុលផុស និងមានប្រសិទ្ធភាព ។

-បន្តយកចិត្តទុកដាក់ខ្ពស់លើការងារប្រមូលផ្តុំវិភាគព័ត៌មានទាំងក្នុង និងក្រៅប្រទេស អំពីការប្រែប្រួលនៃសភាពការណ៍អន្តរជាតិដែលអាចពាក់ព័ន្ធដល់សន្តិសុខជាតិ សំដៅបង្ការ ទប់ស្កាត់មិនឱ្យកើតមានអំពើភេរវកម្មនៅកម្ពុជា បង្ការ ទប់ស្កាត់ បង្ក្រាបប្រកបដោយប្រសិទ្ធភាពនូវនិន្នាការប្រឆាំងរាជរដ្ឋាភិបាល និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ក៏ដូចជាការប្រើប្រាស់បណ្តាញបច្ចេកវិទ្យាព័ត៌មានបំប៉ោងសភាពការណ៍ បង្កចលាចលក្នុងសង្គម...។

-បន្តជំរុញកិច្ចសហការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ឱ្យបានគត់មត់ ដើម្បីបម្រើដល់ដំណើរការនៃព្រឹត្តិការណ៍នយោបាយ និងការរៀបចំកម្មវិធីសំខាន់ៗ ប្រព្រឹត្តទៅដោយជោគជ័យ និងមានសុវត្ថិភាព ។

-បន្តបើកទូលាយកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារអនុវត្តច្បាប់នៃប្រទេសជាមិត្ត ទាំងក្នុង និងក្រៅតំបន់ ដើម្បីទប់ស្កាត់មិនឱ្យកើតមាននូវអំពើភេរវកម្ម បង្ការ ទប់ស្កាត់ និងបង្ក្រាបប្រកបដោយប្រសិទ្ធភាពនូវបទល្មើសឆ្លងដែនគ្រប់ប្រភេទ ។

-បន្តជំរុញការងារស្រាវជ្រាវ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ពិសេសបទល្មើសប្លន់ប្រដាប់អាវុធ គ្រឿងញៀន អំពើជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ចគ្រប់រូបភាព សកម្មភាពក្មេងទំនើង ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដោយជំរុញឱ្យធ្វើការប្រជុំវាយតម្លៃ និងដកពិសោធន៍ជាប្រចាំ ដើម្បីក្តាប់ឱ្យបាននូវសភាពការណ៍ និងឫសគល់នៃបទល្មើស ក្នុងន័យធ្វើការកែសម្រួលយន្តការការងារឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានភាពបត់បែនស្របតាមសភាពការណ៍ប្រែប្រួលនៃបទល្មើស សំដៅបង្កើនប្រសិទ្ធភាពការងារកាន់តែប្រសើរឡើង និងបទល្មើសត្រូវបានកាត់បន្ថយជាអតិបរមា ។

-បន្តរៀបចំសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយ និងបន្តពង្រឹងនិរន្តរភាពនៃការអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកឱ្យបានម៉ឺងម៉ាត់ ព្រមជាមួយការខិតខំជំរុញតាមគ្រប់មធ្យោបាយ និងរូបភាព ក្នុងការផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ និងសាធារណជនទូទៅ ដើរទន្ទឹមនឹងការយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីនគរបាលចរាចរណ៍គ្រប់ថ្នាក់ អំពីច្បាប់ និងបទដ្ឋានសុវត្ថិភាពចរាចរណ៍ ជំនាញបច្ចេកទេស រួមទាំងការពង្រឹងវិន័យ សីលធម៌ អាកប្បកិរិយាក្នុងការបំពេញភារកិច្ច និងភាពជាគំរូក្នុងការអនុវត្តច្បាប់ ។

-បន្តជំរុញការងារផ្សព្វផ្សាយ និងអនុវត្តយន្តការបង្ការ និងពន្លត់អគ្គិភ័យ និងយន្តការគ្រប់គ្រងអាវុធជាតិផ្ទុះ។ ទន្ទឹមនេះ ក៏ត្រូវយកចិត្តទុកដាក់ពិនិត្យ កែសម្រួលយន្តការទាំងនេះឱ្យស្របជាមួយនឹងស្ថានភាពសង្គមផងដែរ ។

-បន្តជំរុញការចាត់តាំងអនុវត្តផែនការ និងយុទ្ធនាការនានារបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមការពារបរិស្ថាន ធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិ ឱ្យបានគង់វង្ស និងវិធានការការពារសន្តិសុខ សុវត្ថិភាព និងការដោះស្រាយសំណូមពរនានាជូនវិនិយោគិន និងភ្ញៀវបរទេស ដើម្បីលើកស្ទួយនយោបាយទេសចរណ៍ជាតិ ។

-បន្តពង្រឹងប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងបន្តគាំទ្រដល់ការបណ្តុះបណ្តាលភ្នាក់ងារសន្តិសុខឯកជន សំដៅកែប្រែកម្លាំងនេះ ឱ្យទៅជាកម្លាំងជំនួយដល់ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

-បន្តពង្រឹង និងថែបំប៉នស្មារតីកងកម្លាំងនគរបាលជាតិគ្រប់ផ្នែក តាមរយៈការយកចិត្តទុកដាក់ទាំងលើកត្តាជីវភាពរស់នៅ ការផ្តល់មធ្យោបាយ សម្ភារៈប្រតិបត្តិការសមស្រប និងការបំពាក់បំប៉នសមត្ថភាពជំនាញ ដើម្បីមានមូលដ្ឋានរឹងមាំក្នុងការការពារខឿនសន្តិសុខជាតិ សុវត្ថិភាពសង្គម បូរណភាពទឹកដី និងឆ្លើយតបសភាពការណ៍នានាបានទាន់ពេលវេលា គ្រប់កាលៈទេសៈ និងអនុលោមតាមក្រមសីលធម៌នៃមន្ត្រីអនុវត្តច្បាប់ ។

-បន្តពង្រឹងយន្តការប្រចាំបញ្ជា និងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ និងខិតខំលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រុមប្រតិកម្មរហ័ស ដើម្បីអន្តរាគមន៍ដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា ។

-បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្លាំងមានសមត្ថកិច្ចនៃប្រទេសជិតខាង ក្នុងការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់តាមតំបន់ព្រំដែន និងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ។

### ៤-ការងារអត្តសញ្ញាណកម្ម

-បន្តគាំទ្រ និងជំរុញដំណើរការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅថ្នាក់ឃុំ សង្កាត់ ដែលកំពុងអនុវត្តសាកល្បងក្នុងខេត្តគោលដៅ និងបន្តពិនិត្យលទ្ធភាពពង្រីកទៅឃុំ សង្កាត់នៃរាជធានី ខេត្តផ្សេងទៀត ។

-បន្តរៀបចំផ្សព្វផ្សាយ ផ្តល់វគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រី អំពីគោលការណ៍ និងលិខិតបទដ្ឋានថ្មីៗ ពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន និងការងារចុះបញ្ជីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ។

-បន្តផ្តល់ និងឆ្លើយតបសំណូមពរនានាជូនប្រជាពលរដ្ឋ លើការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

-បន្តសហការជាមួយគណៈកម្មការអន្តរក្រសួង និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស ។

-បន្តអនុវត្តនីតិវិធីលើករណីសុំរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងពលរដ្ឋខ្មែរ និងករណីសុំចូលសញ្ជាតិខ្មែរ ទាមទារសញ្ជាតិខ្មែរ លះបង់សញ្ជាតិខ្មែរ ។

-បន្តជំរុញលើកកម្ពស់ការផ្តល់សេវារដ្ឋបាលលើការងារអត្តសញ្ញាណកម្ម ដោយផ្តោតជាសំខាន់លើកត្តាពេលវេលា និងលុបបំបាត់ឱ្យបាននូវបាតុភាពអនុវត្តផ្ទុយពីខ្លឹមសារនៃលិខិតបទដ្ឋានជាធរមាន ដើម្បីបម្រើ និងបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋ ។

-បន្តពង្រឹង និងពង្រីកកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីបន្តគាំទ្រដល់ដំណើរការកសាងក្របខ័ណ្ឌច្បាប់ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម និងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ។

**៥-ការងារអន្តោប្រវេសន៍**

-បន្តជំរុញការចាត់តាំងអនុវត្តផែនការ គោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្តដែលនៅជាធរមាន និងបន្ទាន់នានា ។

-លើកកម្ពស់វិធានការគ្រប់គ្រងការចេញចូលប្រទេសឱ្យកាន់តែមានប្រសិទ្ធភាព សំដៅបង្ការ ទប់ស្កាត់មិនឱ្យមានជនបរទេសស្នាក់នៅខុសច្បាប់ បង្ការ ទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ និងការនាំចូលជំងឺកូវីដ-១៩ និងជំងឺកាចសាហាវផ្សេងៗមកក្នុងប្រទេស ។

-បន្តអនុវត្តវិធានការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានមូលដ្ឋានក្នុងការការពារសន្តិសុខ សុវត្ថិភាពជូនជនបរទេស ក៏ដូចជាការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបង្កដោយជនបរទេសប្រកបដោយប្រសិទ្ធភាព ។

-បង្កើនកិច្ចសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគ្រប់គ្រងការប្រកបមុខរបររបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានម៉ត់ចត់ ដើម្បីការពារនយោបាយ"បង្កើតការងារជូនប្រជាជន" របស់រាជរដ្ឋាភិបាលកម្ពុជា ។

-បន្តអនុវត្តនីតិវិធីលើករណីស្នើសុំឋានៈជាជនភៀសខ្លួន និងសុំសិទ្ធិជ្រកកោន ដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្ន សំដៅឆ្លើយតបនូវតួនាទីជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៥១ និងពិធីសារឆ្នាំ១៩៦៧ ពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួនផង និងសំណូមពរនៃការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក៏ដូចជាការអភិវឌ្ឍមាតុភូមិកម្ពុជាផង ។

-បន្តជំរុញវិធានការស៊ើបអង្កេត ស្វែងរកជនបរទេសដែលចូលមកស្នាក់នៅខុសច្បាប់ ស្នាក់នៅហួសរយៈពេលកំណត់ និងជនបរទេសពាក់ព័ន្ធការប្រព្រឹត្តបទល្មើសនានា ដើម្បីចាត់វិធានការច្បាប់ទាន់ពេលវេលា ។

-បន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាអន្តោប្រវេសន៍ ឱ្យមានលក្ខណៈគ្របដណ្តប់បានគ្រប់ជំនាញអន្តោប្រវេសន៍ដែលអាចគាំទ្រប្រកបដោយប្រសិទ្ធភាពនូវតួនាទី ភារកិច្ចក្នុងដំណាក់កាលថ្មីៗ ។

-បន្តជំរុញកិច្ចសហការអន្តរជាតិ ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយដៃគូហត្ថលេខី និងកិច្ចសហការជាមួយប្រទេសជិតខាង និងក្នុងតំបន់ លើការងារអន្តោប្រវេសន៍ ព្រមទាំងបង្កើនសកម្មភាពសហការផ្លាស់ប្តូរព័ត៌មានបម្រើការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទឱ្យមានប្រសិទ្ធភាព ។

## ៦-ការងារពន្ធនាគារ

-បន្តសហការជាមួយស្ថាប័នតុលាការ ដើម្បីគ្រប់គ្រងពន្ធនាគារ ស្របតាមច្បាប់ជាធរមាន ។

-បន្តសិក្សា រៀបចំ និងកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនានា ឱ្យស្របតាមការវិវឌ្ឍនៃវិស័យពន្ធនាគារ ។

-បន្តជំរុញគម្រោងសាងសង់ ជួសជុល កែលម្អអគារឃុំឃាំង និងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងពន្ធនាគារ និងខិតខំអភិវឌ្ឍគ្រប់វិស័យនៃពន្ធនាគារ ដោយសហការជាមួយដៃគូអភិវឌ្ឍនានា សំដៅលើកកម្ពស់ការអនុវត្តកម្មវិធីអប់រំកែប្រែ ស្តារនីតិសម្បទា កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ កម្មវិធីសមាហរណកម្ម និងសេវាសុខភាព។

-បន្តពង្រឹងការអនុវត្តវិធានការការពារសន្តិសុខ សុវត្ថិភាពពន្ធនាគារ ដើរទន្ទឹមនឹងការយកចិត្តទុកដាក់ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីពន្ធនាគារជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើស និងហានិភ័យផ្សេងៗ ដែលអាចនឹងកើតមានជាយថាហេតុ ។

## ៧-ការងារបណ្ឌិត្យសភានគរបាលកម្ពុជា

-បន្តពិនិត្យ រៀបចំ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌគតិយុត្តចាំបាច់នានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងគុណភាពអប់រំ និងធានាបានក្នុងភាពម្ចាស់ការលើការងារបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ។

-បន្តពង្រឹងគុណវុឌ្ឍិគ្រូនគរបាលជាតិ និងគុណភាពសិក្សារបស់និស្សិត សិក្ខាកាម ។

-បន្តពង្រីកវិសាលភាព និងលើកកម្ពស់កម្មវិធីបណ្តុះបណ្តាល បំពាក់បំប៉នមុខជំនាញឯកទេសដល់និស្សិត និងសិក្ខាកាម ដែលជាមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារ ។

-បន្តអភិវឌ្ឍកម្មវិធីសិក្សា ខ្លឹមសារមេរៀន និងខិតខំចងក្រងឯកសារសម្រាប់បង្ហាត់បង្រៀននិស្សិត សិក្ខាកាមគ្រប់កម្រិតសិក្សា ។

-បន្តជំរុញ និងគាំទ្រការងារអភិវឌ្ឍធនធានសិក្សា និងធនធានរូបវន្តគ្រប់ប្រភេទ ព្រមទាំងផ្គត់ផ្គង់សម្ភារៈបច្ចេកទេស ឱ្យបានសមស្រប ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលគ្រប់វគ្គ និងគ្រប់កម្រិត ។

-បន្តអនុវត្តប្រព័ន្ធធានាគុណភាពអប់រំទ្វេភាព (ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងការវាយតម្លៃទទួលស្គាល់គុណភាពអប់រំពីខាងក្រៅ) ដើម្បីធ្វើឱ្យគុណភាពអប់រំប្រសើរឡើងជាលំដាប់ ។

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីកៀរគរជំនួយបច្ចេកទេស សម្ភារៈ ហិរញ្ញវត្ថុ ជាពិសេស ដើម្បីសិក្សា ស្រាវជ្រាវ និងផ្លាស់ប្តូរបទពិសោធន៍ការងារបង្ហាត់បង្រៀន និងកម្មវិធីអប់រំសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល ។

## ៨-ការងារគណនេយ្យ និងហិរញ្ញវត្ថុ

-បន្តសម្របសម្រួល និងគាំទ្រដល់អង្គភាពក្រោមឱវាទក្នុងការរៀបចំកម្មវិធីចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុរបាយការណ៍សមិទ្ធកម្ម ។

-បន្តអនុវត្តនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បន្តជំរុញការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងលទ្ធកម្មសាធារណៈ ឱ្យស្របតាមប្រក្រតិទិនកំណត់ ចៀសវាងមានការកកស្ទះនៅចុងឆ្នាំ ។

-បន្តតាមដាន និងជំរុញពន្លឿនការអនុវត្តគម្រោងជួសជុល និងសាងសង់សំណង់គ្រប់ប្រភេទ ដែលកំពុងដំណើរការ និងបន្តសិក្សា រៀបចំគម្រោងនានាបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ។

-បន្តស្វែងយល់អំពីតម្រូវការ និងបរិមាណ គុណភាពនៃឧបករណ៍ សម្ភារៈបច្ចេកទេស ដែលប្រទេសមួយចំនួនកំពុងប្រើប្រាស់ សំដៅបង្កើនប្រសិទ្ធភាពដល់កិច្ចប្រតិបត្តិការនានាស្ថិតក្នុងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ ។

-បន្តជំរុញការផ្សព្វផ្សាយអប់រំសុខភាពដល់នគរបាលជាតិនៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងលើកកម្ពស់សមត្ថភាពជំនាញរបស់មន្រ្តីពេទ្យ ព្រមជាមួយនឹងការយកចិត្តទុកដាក់ផ្គត់ផ្គង់សម្ភារៈបច្ចេកទេសបរិក្ខារវេជ្ជសាស្រ្ត ឱ្យសមស្រប ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការព្យាបាលជំងឺជូនកងកម្លាំងនគរបាលជាតិ ។

### ៩-ការងារអធិការកិច្ច

-បន្តពង្រឹងយន្តការទទួលពាក្យបណ្តឹង និងការតាមដានប្រមូលព័ត៌មានពីគ្រប់ប្រភពសារព័ត៌មាន ព្រមទាំងជំរុញការចុះអធិការកិច្ច អង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹង ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។

-បន្តជំរុញការចុះអធិការកិច្ចលើសេចក្តីជូនដំណឹងនានាដែលក្រសួងបានដាក់ចេញ និងបណ្តាសំណុំរឿងដែលក្រសួងបង្វែរជូនអង្គភាពពាក់ព័ន្ធអនុវត្តជាសមត្ថកិច្ច នាពេលកន្លងមក ។

### ១០-ការងារសវនកម្មផ្ទៃក្នុង

-បន្តប្រតិបត្តិដោយយកចិត្តទុកដាក់នូវរាល់គោលការណ៍ណែនាំ និងបែបបទកំណត់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ សំដៅពង្រឹងប្រសិទ្ធភាពការងាររបស់ក្រសួងឱ្យកាន់តែមានប្រសិទ្ធភាព ។

-ត្រៀមអនុវត្តកម្មវិធីចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០២០ និងឆ្នាំពាក់ព័ន្ធ នៅតាមបណ្តាគោលដៅសវនដ្ឋាន ព្រមជាមួយនឹងការបន្តខិតខំប្រមូលឯកសារ ទិន្នន័យ និងភស្តុតាងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ពីបណ្តាអង្គភាពជំនាញចំណុះទីស្តីការក្រសួង និងបណ្តាសវនដ្ឋាននៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានក្នុងការជំរុញឱ្យការងារសវនកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

### ១១-ការងារទំនាក់ទំនងអន្តរជាតិ

-បន្តទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូអន្តរជាតិដែលអញ្ជើញមកបំពេញទស្សនកិច្ច និងពិភាក្សាការងារ ។

-បន្តពង្រឹង ពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឱ្យកាន់តែរឹងមាំ និងទូលំទូលាយ សំដៅជំរុញលើកកម្ពស់នូវគ្រប់ក្របខ័ណ្ឌការងារដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ក៏ដូចជាបម្រើដល់ឧត្តមប្រយោជន៍ជាតិទាំងមូល ពិសេសលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យរដ្ឋបាលសាធារណៈ ។

### ១២-ការងារអភិវឌ្ឍធនធានមនុស្ស

-បន្តពង្រឹងរបៀបរបបការងារនៅតាមអគ្គនាយកដ្ឋាន អង្គភាពថ្នាក់ប្រហាក់ប្រហែល អង្គភាពចំណុះ និងនៅថ្នាក់ក្រោមជាតិ និងពង្រឹងការគ្រប់គ្រង និងការបំពេញការងាររបស់មន្ត្រី ទាំងមន្រ្តីរដ្ឋបាលស៊ីវិល មន្រ្តីពន្ធនាគារ និងមន្រ្តីនគរបាលជាតិ នៅគ្រប់លំដាប់ថ្នាក់ ។

-បន្តជំរុញដំណើរការវិភាគមុខងារ ដើម្បីកំណត់មុខតំណែង និងក្របខ័ណ្ឌសម្រាប់រយៈពេលខ្លី និងរយៈពេលពីមធ្យមទៅរយៈពេលវែង នៅតាមអគ្គនាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃ ។

-បន្តពិនិត្យលទ្ធភាពផ្តល់វគ្គបំប៉ន និងវគ្គបណ្តុះបណ្តាលចាំបាច់នានា ដល់មន្ត្រីនៅគ្រប់លំដាប់ថ្នាក់ ដើម្បីលើកកម្ពស់សមត្ថភាពបំពេញការងារឱ្យឆ្លើយតបទៅនឹងតម្រូវការ ។

-បន្តជំរុញការអនុវត្តកំណែទម្រង់នគរបាលជាតិឱ្យបានស៊ីជម្រៅទាំងការបណ្តុះបណ្តាល បំពាក់បំប៉នជំនាញឯកទេសចាំបាច់ ការវិភាគមុខងារ ការត្រួតពិនិត្យ កែសម្រួលរចនាសម្ព័ន្ធតាមសភាពការណ៍ ការគ្រប់គ្រងកម្លាំង និងការពង្រឹងវិន័យ សីលធម៌ គុណធម៌ ដើម្បីឱ្យនគរបាលជាតិក្លាយជាកម្លាំងរៀបរយ បម្រើប្រជាជនដោយភក្តីភាព និងមានមនសិការវិជ្ជាជីវៈពិតប្រាកដ ។

-បន្តចាត់បញ្ជូនមន្ត្រីទៅធ្វើទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា និងសិក្សាឯកទេសនៅបរទេសតាមផែនការសហប្រតិបត្តិការជាមួយប្រទេសនានា ។

**ឧ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

សក់ សេដ្ឋា

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (គណៈកម្មការទី៤)
-អគ្គលេខាធិការដ្ឋានរដ្ឋសភា (គណៈកម្មការទី៤)
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-អង្គភាពចំណុះក្រសួងមហាផ្ទៃ
-ឯកសារ-កាលប្បវត្តិ